**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការចោទប្រកាន់ និងការតម្កល់រឿង ទុកឥតចាត់ការរបស់ស្ថាប័ន អយ្យការ នាពេលបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ឡឹង សំអឿន**

**លោក មុត ពិសី**

ណែនាំដោយ

**លោក មីន សំអុល**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឡឹម សំអឿន** និង **មុត ពិសី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ដែលជាបឋមខ្ញុំទាំងពីរនាក់សូមគោរពបន្ទន់កាយសម្ដែងនូវកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតចំពោះលោកឪពុក **ឡឹម រដ្ឋ** និងអ្នកម្ដាយ **ឃី ថុន** ព្រមទាំងលោកឪពុក **ហ៊ឹម ទិសាល** និងអ្នកម្ដាយ **ស៊ិន សមណា** ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន និងឧបត្ថម្ភគ្រប់បែបយ៉ាងតាំងពីចាប់កំណើតរហូតមកដល់ពេលនេះ។ លោកអ្នកមានគុណបានលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងធ្វើពលិកម្មគ្រប់បែបយ៉ាងតស៊ូរាល់គ្រប់ឧបគ្គដោយមិនខ្លាចនឿយហត់ដើម្បីចិញ្ចឹមបីបាច់ថែរក្សាបុត្រភ្ញារ ព្រមទាំងបានផ្ដល់នូវកម្លាំងកាយ កម្លាំងចិត្ត ទាំងផ្នែកប្រាជ្ញាស្មារតី សម្ភារ បរិក្ខា សម្រាប់ទំនុកបម្រុងការសិក្សារបស់យើងខ្ញុំចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សាប្រកបដោយជោគជ័យ។ ឧបការគុណដ៏មហិមារ និងថ្លៃថ្លារបស់លោកទាំងទ្វេ យើងខ្ញុំជាកូនៗមិនអាចបំភ្លេច និងរៀបរាប់ឲ្យបានអស់នោះទេ យើងខ្ញុំជាកូនៗ សូមធ្វើការប្ដេជ្ញាចិត្តនឹងខិតខំរៀនសូត្រ និងមិនប្រព្រឹត្តអំពើអបាយមុខទាំងឡាយណាដែលមិនល្អដល់ខ្លួន គ្រួសារ និងសង្គមជាតិឡើយ។

ស្ថិតក្នុងបរិបទនេះអ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណជាអនេកប្បការចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកសិក្សា ដែលបានខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់លះបង់កម្លាំងកាយ និងកម្លាំងចិត្តក្នុងកិច្ចការដឹកនាំ គ្រប់គ្រង ពិសេសគឺការបង្ហាត់បង្ហាញបង្រៀន និងផ្ដល់ចំណេះដឹងគ្រប់បែបយ៉ាងដល់យើងខ្ញុំមកទល់នឹងពេលនេះ។

ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាពិសេសបំផុតចំពោះ លោក **មីន សំអុល** ដែលលោកបានចំណាយពេលដ៏មានតម្លៃ យកចិត្តទុកដាក់ក្នុងការបង្រៀន បង្ហាត់បង្ហាញព្រមទាំងផ្ដល់នូវដំបូន្មានល្អៗ នៃបទពិសោធន៍របស់លោក ក្នុងការតាក់តែង និងកែលំអលើ សារណា ដោយបានពន្យល់ណែនាំនូវវិធីសាស្ត្រនៅក្នុងការស្រាវជ្រាវ ប្រមូលព័ត៌មាននានាមកធ្វើការចងក្រងជា ***សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ*** មួយនេះឡើងប្រកបដោយភាពប្រាកដប្រជាមួយ ដែលនឹងអាចទទួលបានជោគជ័យនាពេលពេលខាងមុខជាក់ជាមិនខាន។

ជាចុងក្រោយ ខ្ញុំបាទទាំងពីរនាក់សូមឆ្លៀតឱកាសដ៏មានតម្លៃនេះ ដើម្បីប្រសិទ្ធពរជ័យជូនចំពោះលោកឪពុក អ្នកម្ដាយ លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកសិក្សានិងអ្នកមានគុណទាំងអស់ សូមពើបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើន និងសមប្រកបដោយពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជារៀងរហូតទៅកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ស្ថិតក្នុងបដិការនៃការសិក្សាទៅលើផ្នែកនីតិសាស្ត្រ ក្នុងអំឡុងពេលប្រមាណ៤ឆ្នាំកន្លងមក នៅឯសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំពិតជាមានក្តីសោមនស្សនិងភាពសប្បាយរីករាយជាខ្លាំងដោយមានកិត្តិយសបានចូលរួមរៀបចំចងក្រងសិក្សាស្រាវជ្រាវ និងធ្វើជាសារណាដើម្បីបញ្ចប់ការសិក្សានេះឡើង ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍នូវចំណេះដឹងបន្ថែមឲ្យកាន់តែទូលំទូលាយ និងកាន់តែមានភាពស៊ីជម្រៅទៅលើ ***ស្ថាប័នអយ្យការ ការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការរបស់ អយ្យការ*** តាមរយៈការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តីច្បាប់ និងការអនុវត្តន៍ការងារជាក់ស្តែងរបស់ស្ថាប័នអយ្យការនៅកម្ពុជា។ ក្នុងនាមយើងខ្ញុំជាក្រុមនិស្សិតនីតិសាស្ត្រ យើងខ្ញុំនឹងខិតខំប្រឹងប្រែងឲ្យអស់ពីកម្លាំងកាយចិត្ត ក្នុងការរៀបចំចងក្រងសារណាបញ្ចប់ការសិក្សានេះឡើងប្រកបដោយភាពជោគជ័យ ដោយមានការជួយជម្រុញពី លោក **មីន សំអុល** ជាអ្នកសម្របសម្រួលក្នុងការរៀបចំចងក្រងនូវកិច្ចការស្រាវជ្រាវជាសារណានេះឡើង។

បើអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជាត្រង់មាត្រា ១៣១ថ្មី បានផ្តល់អំណាចផ្តាច់មុខទៅឲ្យអង្គការអយ្យការសម្រាប់ធ្វើបណ្តឹងអាជ្ញា។ ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋដែលតំណាងឲ្យអង្គការនីតិប្រតិបត្តិ និងជាម្ចាស់នៃបណ្តឹងអាជ្ញា ដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ សម្រាប់ដំណើរការបណ្តឹងឲ្យមានសកម្មភាពងាយស្រួលក្នុងការស្វែងរកយុត្តិធម៌សម្រាប់សង្គមជាតិ។ ម្ចាស់នៃបណ្តឹងអាជ្ញានេះ ជាស្ថាប័នមួយដែលមានសារៈសំខាន់ណាស់នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ព្រោះជាអ្នកតំណាងឲ្យសង្គម និងជាអ្នកការពារផលប្រយោជន៍សាធារណៈ និងមានសិទ្ធិក្នុងការប្រើប្រាស់នូវជម្រើសនៃការចោទប្រកាន់របស់ខ្លួនចំពោះបទល្មើសព្រហ្មទណ្ឌ ធ្វើឲ្យបណ្តឹងអាជ្ញាទាំងឡាយអាចដំណើរការបាន ដើម្បីស្វែងរកយុត្តិធម៌ និងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ ហេតុដូចនេះហើយទើបបានជាយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយគឺ **«ការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការរបស់ស្ថាប័នអយ្យការ»**សម្រាប់សិក្សាស្រាវជ្រាវ។

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាដែលយើងខ្ញុំបានស្ថាបនាឡើងនេះ នឹងក្លាយជាឯកសារផ្នែកច្បាប់មួយដ៏មានសារៈប្រយោជន៍ និងជាជំនួយដល់និស្សិតជំនាន់ក្រោយៗ និងអ្នកសិក្សាស្រាវជ្រាវទាំងឡាយក្នុងការពង្រឹងនូវចំណេះដឹងបន្ថែមរបស់ពួកគេ ទាក់ទងទៅនឹងស្ថាប័នអយ្យការ រួមទាំងជម្រើសនៃការចោទប្រកាន់របស់ស្ថាប័ននេះ ដើម្បីលើកស្ទួយវិស័យច្បាប់ឲ្យកាន់តែមានភាពប្រសើរឡើង។ ការលេចចេញជារូបរាងនិងផ្លែផ្ការបស់សារណានេះ ពិតជាមាននូវចំណុចខ្វះខាតជាអន្លើនឹងកើតឡើងជាក់ជាពុំខានទាំងផ្នែកអក្ខរាវិរុទ្ធ អត្ថន័យនិងអត្ថរស់ ដូច្នេះខ្ញុំបាទទាំងពីរនាក់រីករាយស្វាគមន៍ទទួលរាល់ការផ្តល់មតិយោបល់ និងការរិះគន់ក្នុងន័យស្ថាបនាផ្សេងៗ ពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងអ្នកសិក្សាស្រាវជ្រាវទាំងឡាយដោយក្តីសោមនស្សរីករាយ ដើម្បីធ្វើឲ្យសារណានេះកាន់តែមានលក្ខណៈប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា


**សេចក្តីផ្តើម** **ទំព័រ**

១. លំនាំបញ្ហានៃការស្រាវជ្រាវ....................១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ....................២

៣. គោលបំណងនៃការស្រាវជ្រាវ....................២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ....................៣

 ៤.១. ទំហំ....................៣

 ៤.២. ដែនកំណត់....................៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ....................៣

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ....................៤

 ៦.១. វិធីសាស្រ្តប្រមូលទិន្នន័យ....................៤

 ៦.២. វិធីសាស្រ្តវិភាគទិន្នន័យ....................៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....................៥

**ជំពូកទី១**

**សញ្ញាណទូទៅនៃស្ថាប័នអយ្យការ**

**ផ្នែកទី១ ៖ រចនាសម្ព័ន្ធរបស់ស្ថាប័នអយ្យការ**....................៦

១. មហាអយ្យការអមតុលាការកំពូល....................៧

២. មហាអយ្យការអមសាលាឧទ្ធរណ៍....................៧

៣. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត....................៨

៤. អយ្យការអមតុលាការយោធា....................៩

**ផ្នែកទី២ ៖ សមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អង្គការអយ្យការ**....................១០

១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា....................១០

២. តួនាទីរបស់ព្រះរាជអាជ្ញា....................១០

៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា....................១១

៤. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា....................១២

**ផ្នែកទី៣ ៖ គោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ**....................១៣

១. គោលការណ៍អវិភាគ......១៣
២. គោលការណ៍ឯកភាព (គោលការណ៍ឋានានុក្រម) ......១៣
៣. គោលការណ៍ឯករាជ្យ ......១៤
៤. គោលការណ៍មិនអាចប្តឹងដិតចិត្ត......១៤
៥. គោលការណ៍នៃការមិនទទួលខុសត្រូវ ......១៥

## ជំពូកទី២

## ការចោទប្រកាន់របស់អយ្យការ នាពេលបច្ចុប្បន្ន

**ផ្នែកទី១ ៖ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ** ...... ១៦
១. លក្ខខណ្ឌដែលធ្វើឲ្យមានចំណាត់ការក្នុងការបើកការស៊ើបសួរ......១៧
២. នីតិវិធី និងទម្រង់នៃការបើកការស៊ើបសួរ ...... ១៨
២.១. ការបើកការស៊ើបសួរដោយទទួលពាក្យប្តឹងដែលបញ្ជូនមក ...... ១៨
២.២. ការបើកការស៊ើបសួរដោយទទួលសំណុំរឿងពីមន្រ្តីនគរបាលយុត្តិធម៌ ...... ១៩
២.៣. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យធ្វើការស៊ើបសួរ......២០
៣. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ......២០
**ផ្នែកទី២ ៖ ការចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**......២១
១. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់......២២
១.១. លក្ខខណ្ឌនៃបទល្មើស ......២២
១.២. អត្តសញ្ញាណរបស់ជនល្មើស...... ២៣
២. នីតិវិធី និងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់......២៤
៣. លក្ខខណ្ឌដែលនាំឲ្យមានសុពលភាពលើដីកាកោះហៅទៅជំនុំជម្រះផ្ទាល់......២៤
៤. អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ......២៥
**ផ្នែកទី៣ ៖ ការចោទប្រកាន់តាមរយៈកំណត់ហេតុបង្ហាញខ្លួនភ្លាម** ......២៦
១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម......២៦
២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម......២៧
២.១. នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា......២៧
២.២. នីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ ......២៨
៣. អានុភាពនៃការបង្ហាញខ្លួនភ្លាម......២៨

## ជំពូកទី៣
## ការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ នាពេលបច្ចុប្បន្ន

**ផ្នែកទី១ ៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**.......................................................៣០
១. នត្ថិភាពនៃបទល្មើស ...................................................................................................៣១
  ១.១. អវត្តមាននៃបទល្មើស.........................................................................................៣១
  ១.២. ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់ ........................................................................៣១
២. មូលហេតុគតិយុត្ត.......................................................................................................៣២
  ២.១. ការរលត់នៃបណ្ដឹងអាជ្ញា ....................................................................................៣២
  ២.២. មូលហេតុគតិយុត្តផ្សេងទៀត ................................................................................៣៥
៣. ការចោទប្រកាន់មិនផ្ដល់ផលប្រយោជន៍ .........................................................................៣៨
៤. ជម្រើសនៃការណែនាំ...................................................................................................៣៩
**ផ្នែកទី២ ៖ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ** ...............................................៣៩
១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ........................................................................៣៩
២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ .......................................................................៤០
**ផ្នែកទី៣ ៖ យន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ** .......................................................៤០
១. បណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ..........................................................៤១
២. អំណាចអធិបញ្ជាដោយឋានានុក្រមនៃអង្គការអយ្យការ ....................................................៤២
  ២.១. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ......................................................................................៤២
  ២.២. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.......................................................................៤៣
  ២.៣. ព្រះរាជអាជ្ញា.....................................................................................................៤៣
  ៣. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ .............................៤៤
**សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍**
១. សេចក្ដីសន្និដ្ឋាន .........................................................................................................៤៥
២. ការផ្ដល់អនុសាសន៍ .....................................................................................................៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

រយៈពេលជាង ៣ ទសវត្សន៍ បានធ្វើឲ្យប្រទេសកម្ពុជាធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិល រហូតដល់ឆ្នាំ ១៩៩៣ បដិការការចរចារនៃ សន្ធិសញ្ញាទីក្រុងប៉ារីស ទើបព្រះរាជាណាចក្រកម្ពុជាទទួលបានសុខសន្តិភាពពិតប្រាកដ។ ក្នុងរយៈពេលជាង ៣ទស្សវត្សន៍នេះ ព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់៥សម័យកាលមកក្រោមរូបភាព នៃសង្គ្រាមរវាងខ្មែរនិងខ្មែរគ្នាឯង បានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋមានការប្រែប្រួលទៅតាមសម័យកាល ដែលបានធ្វើឲ្យប្រព័ន្ធច្បាប់សំខាន់ៗលែងមានអានុភាពក្នុងការគ្រប់គ្រងប្រទេសតទៅទៀត។ នៅក្នុងឆ្នាំ ១៩៩៣ សន្ធិសញ្ញាទីក្រុងប៉ារីស បានធ្វើឲ្យប្រទេសកម្ពុជាចាប់ផ្តើមកកើតរដ្ឋក្លាយជាព្រះរាជាណាចក្រកម្ពុជាទី២ រហូតដល់បច្ចុប្បន្ននេះ។ ដើម្បីបង្ការមិនឲ្យមានភាពចលាចលក្នុងស្រុកម្តងទៀត និងរក្សាសណ្តាប់ធ្នាប់របៀបរៀបរយក្នុងសង្គម រាជរដ្ឋាភិបាលបានផ្តួចផ្តើមធ្វើការបង្កើតឡើងនូវច្បាប់សំខាន់ៗសម្រាប់គ្រប់គ្រងរដ្ឋ។

ក្រោមការជួយជ្រោមជ្រែងពីសំណាក់អង្គការសហប្រជាជាតិ កម្ពុជាបានបង្កើតនូវច្បាប់នីតិវិធីមួយឡើង នៅក្នុងឆ្នាំ១៩៩៣។ នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នីតិវិធីនេះ បានប្រគល់អំណាចឲ្យទៅព្រះរាជអាជ្ញាជាម្ចាស់បណ្តឹង ដែលអាចធ្វើការចោទប្រកាន់ និងបញ្ជូនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសតាមផ្លូវច្បាប់។ ព្រះរាជអាជ្ញាធ្វើការក្នុងនាមជាតំណាងឲ្យរដ្ឋ តំណាងឲ្យផលប្រយោជន៍រួមនៃសង្គម ដូចនេះ នៅពេលដឹងថាមានបទល្មើសកើតឡើង ព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅពីធ្វើការចោទប្រកាន់បញ្ជូនជនត្រូវចោទទៅចៅក្រមស៊ើបសួរសោះឡើយ។ ជាបឋមគេនឹកស្មានថាជម្រើសតែមួយមុខ គឺការចោទប្រកាន់ឲ្យបើកការស៊ើបសួររបស់ព្រះរាជអាជ្ញាគឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីស្វែងរកយុត្តិធម៌ជូនគូរភាគី។ ប៉ុន្តែ ជារឿយៗការធ្វើសកម្មភាពដដែលៗរបស់ព្រះរាជអាជ្ញានេះ បានធ្វើឲ្យកំណើនរឿងក្តីស៊ើបសួរកាន់តែមានកំណើនច្រើនឡើងៗ រហូតធ្វើឲ្យក្លាយទៅជារឿងអយុត្តិធម៌ចំពោះគូរភាគី ទៅវិញ។ បើក្រឡេកមើលច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩៣ ជាច្បាប់មួយពុំបានចែងឲ្យបានលម្អិតអំពីនីតិវិធីក្នុងកិច្ចដំណើររឿងក្តីព្រហ្មទណ្ឌនោះទេ ដែលចន្លោះប្រហោងផ្នែកច្បាប់តម្រូវនូវភាពអវិជ្ជមានទាំងនោះ។ ប៉ុន្តែរហូតដល់ឆ្នាំ ២០០៧ ដើម្បីធ្វើការដោះស្រាយនូវភាពអវិជ្ជមាន និងកំណើននៃសំណុំរឿងក្តីស៊ើបសួរធ្វើឲ្យមានភាពប្រសើរជាងមុន កម្ពុជាបានបង្កើតនូវក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ត្រូវបានចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ហើយបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលរួមមានច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់នីតិវិធីព្រហ្មទណ្ឌអន្តរកាល ត្រូវបាននិរាករណ៍ដោយក្រមថ្មីនេះ។ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រូវបានចែកចេញជា ១១គន្លី និងមាន៦១២មាត្រា ដែលគន្លីនីមួយៗមានការបែងចែកពីនីតិវិធី តួនាទីភារកិច្ច របស់បុគ្គលដែលមានសិទ្ធិក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្នុងគន្លីទី២ អង្គការអយ្យការ គឺជាស្ថាប័នឯករាជ្យដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា

អគ្គព្រះរាជអាជ្ញារង ព្រមទាំងមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងសាលាដំបូងនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជួយសម្របសម្រួល និងរក្សាសណ្តាប់ធ្នាប់សាធារណៈផងដែរ។ ក្រមនីតិវិធីនេះបានផ្តល់អំណាចឲ្យព្រះរាជអាជ្ញាអាចមានជម្រើសច្រើនជាងមុន គឺអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬចោទប្រកាន់ឲ្យបើកការស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះជាអាទិ៍។ ជម្រើសទាំងអស់នេះ គឺជាមធ្យោបាយថ្មីមួយចំពោះចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌរបស់ស្ថាប័នអយ្យការ។

ដោយហេតុដូចច្នេះហើយ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីវិសាលភាពនៃនីតិវិធីថ្មីនេះទើបអ្នកស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយស្តីពី «**ការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការរបស់ស្ថាប័នអយ្យការ នាពេលបច្ចុប្បន្ន**» មកធ្វើការសិក្សាស្រាវជ្រាវ ដោយផ្តោតសំខាន់ទៅលើលក្ខខណ្ឌ និងនីតិវិធីនៃការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ ព្រមទាំងមូលហេតុ និងនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថា នៅក្នុងរឿងក្តីព្រហ្មទណ្ឌអយ្យការបានដើរតួនាទីយ៉ាងសំខាន់បំផុត ក្នុងការការពារផលប្រយោជន៍សាធារណៈ។ ចំពោះការធ្វើបណ្តឹងអាជ្ញា ឬការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ គឺជាតួនាទីតែមួយគត់របស់តំណាងអយ្យការ។ ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់អំពីជម្រើសនៃការចោទប្រកាន់ ឬមិនចោទប្រកាន់របស់ស្ថាប័នអយ្យការ យើងគួរតែសិក្សាយល់ដឹងអំពី៖

- តើតំណាងអយ្យការមានជម្រើសនៅក្នុងការចោទប្រកាន់ទៅលើរឿងក្តីព្រហ្មទណ្ឌយ៉ាងដូចម្តេចខ្លះ?
- តើតំណាងអយ្យការត្រូវអនុវត្តន៍លក្ខខណ្ឌ និងនីតិវិធីដូចម្តេចខ្លះ ដើម្បីសម្រេចធ្វើការចោទប្រកាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ?
- តើមានមូលហេតុអ្វីខ្លះដែលតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ ឬសម្រេចតម្កល់រឿងទុកឥតចាត់ការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវទាក់ទងទៅនឹងជម្រើសនៃការចោទប្រកាន់របស់ស្ថាប័នអយ្យការ គឺផ្តោតទៅលើចំណុចមួយចំនួនដូចជា៖

- សិក្សាទៅលើស្ថានភាពទូទៅរបស់ស្ថាប័នអយ្យការ
- សិក្សាទៅលើរចនាសម្ព័ន្ធ តួនាទី និងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ
- សិក្សាអំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ
- សិក្សាពីមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ

- សិក្សាអំពីនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ
- សិក្សាពីយន្តការជម្រុញឲ្យមានការចោទប្រកាន់រឿងក្ដីព្រហ្មទណ្ឌឡើងវិញ
- ការធ្វើសេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍ ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៤.១. ទំហំ

ស្ថាប័នអយ្យការ ជាស្ថាប័នរបស់រដ្ឋមួយដែលមាននៅអមគ្រប់តុលាការទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាមូលហេតុធ្វើឲ្យក្រុមយើងខ្ញុំ មិនអាចធ្វើការសិក្សាស្រាវជ្រាវលម្អិតបានគ្រប់ស្ថាប័នអយ្យការអមនៅតុលាការទាំងអស់នោះបានទេ។ ដូច្នេះ ក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ គឺក្រុមយើងខ្ញុំផ្ដោតសំខាន់តែលើប្រធានបទ ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្តតែប៉ុណ្ណោះ។

### ៤.២. ដែនកំណត់

ដោយផ្អែកទៅលើប្រធានបទដែលបានកំណត់រួច ការសិក្សាស្រាវជ្រាវនេះ គឺស្រាវជ្រាវផ្ដោតការយកចិត្តទុកដាក់ និងស៊ីជម្រៅតែទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- ការចោទប្រកាន់ទៅលើរឿងក្ដីព្រហ្មទណ្ឌរបស់អយ្យការ
- នីតិវិធីនៃការចោទប្រកាន់របស់អយ្យការ
- ការមិនចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ
- នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទជម្រើសនៃការចោទប្រកាន់របស់ស្ថាប័នអយ្យការ ផ្ដល់សារៈសំខាន់មួយចំនួនដូចជា៖

- ទទួលបានចំណេះដឹងថ្មីៗទាក់ទងនឹងការស្រាវជ្រាវ និងយល់ដឹងកាន់តែលម្អិតទាក់ទងប្រធានបទ
- យល់ដឹងពីស្ថានភាពទូទៅរបស់ស្ថាប័នអយ្យការនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- យល់ដឹងពីរចនាសម្ព័ន្ធ តួនាទី និងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ
- យល់ដឹងពីសមត្ថកិច្ច តួនាទី ភារៈកិច្ច និងសិទ្ធអំណាចរបស់ព្រះរាជអាជ្ញា
- យល់ដឹងពីលក្ខខណ្ឌនៃការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ
- យល់ដឹងពីនីតិវិធី និងអានុភាពក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌរបស់អយ្យការ
- យល់ដឹងពីមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ

- យល់ដឹងពីនីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ
- យល់ដឹងពីយន្តការជម្រុញឲ្យមានការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌឡើងវិញ
- ពង្រឹងចំណេះដឹងបន្ថែមទាក់ទងដំណើរការចោទប្រកាន់របស់ស្ថាប័នអយ្យការ
- ធ្វើការកែប្រែនូវចំណុចអវិជ្ជមានផ្សេងៗ ដើម្បីឲ្យដំណើរការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ របស់អយ្យការកាន់តែមានភាពប្រសើរឡើងថែមមួយកម្រិតទៀត
- ផ្តល់ជាឯកសារទុកសម្រាប់សិស្សនិស្សិត អ្នកសិក្សា និងអ្នកស្រាវជ្រាវជំនាន់ក្រោយ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងបានធ្វើការប្រមូលព័ត៌មាន និងទិន្នន័យមកសំអាងពីទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។ ដើម្បីឲ្យដំណើរការនៃការស្រាវជ្រាវនេះប្រកបដោយភាពជោគជ័យ យើងទាមទារនូវតម្រូវការទិន្នន័យជាច្រើន ដែលទទួលបានពីប្រភពចម្បងពីរ ដែលសម្រួលក្នុងការប្រមូលទិន្នន័យ និងវិភាគឲ្យគ្រប់គ្រាន់គឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

#### ក. ទិន្នន័យចម្បង

ទិន្នន័យចម្បង ជាទិន្នន័យដែលទទួលបានតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម៖

- ការសាកសួរយោបល់ពីសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ និងសាស្ត្រាចារ្យណែនាំ
- ការសាកសួរតាមប្រព័ន្ធទំនាក់ទំនងសង្គមជាមួយមន្ត្រីស្ថាប័នរដ្ឋ និងព្រះរាជអាជ្ញានៅសាលាដំបូង
- ការសាកសួរទៅកាន់សិស្សច្បង និងមិត្តភក្តិដែលសិក្សាផ្នែកនីតិសាស្ត្រ។

#### ខ. ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យដែលទទួលបានតាមមធ្យោបាយមួយចំនួនដូចខាងក្រោម៖

- លិខិតបទដ្ឋានគតិយុត្ត និងច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ឯកសារ និងទ្រឹស្តីដែលបានមកពីការសិក្សាជាមួយសាស្ត្រាចារ្យនៅសាកលវិទ្យាល័យកន្លងមក
- សៀវភៅពុម្ព និងឯកសាររបស់សាស្ត្រាចារ្យដែលទាក់ទងនឹងស្ថាប័នអយ្យការ និងនីតិវិធីព្រហ្មទណ្ឌ
- សារណាស្រាវជ្រាវរបស់និស្សិតនីតិស្រាស្តជំនាន់មុន
- ការស្រាវជ្រាវនៅតាមបណ្ណាល័យ តូបសៀវភៅ និងបណ្ណាគារផ្សេងៗ

- ការស្រាវជ្រាវបន្ថែមតាមប្រព័ន្ធអ៊ីនធើណែត និងតាមប្រភពផ្សេងៗទៀត។

### ៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

ចំពោះវិធីសាស្ត្រវិភាគទិន្នន័យ ដែលប្រើប្រាស់ក្នុងការវិភាគសារណា ដែលទាក់ទងទៅនឹងជម្រើសនៃការចោទប្រកាន់របស់ស្ថាប័នអយ្យការនេះ គឺត្រូវបានកំណត់ និងអនុវត្តន៍នូវវិធីសាស្ត្រតាមបែបគុណភាព និងមិនធ្វើតាមបែបបរិមាណនោះទេ។ សម្រាប់ការវិភាគទិន្នន័យ គឺក្រុមយើងខ្ញុំយកទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំដែលប្រមូលបានមកវិភាគ ដើម្បីឈានទៅដល់ការទាញចេញជាសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកចេញជាបីជំពូកដូចខាងក្រោម៖

**ជំពូកទី១** : សញ្ញាណទូទៅនៃស្ថាប័នអយ្យការ ៖ រៀបរាប់អំពីស្ថាប័នអយ្យការទាក់ទងនឹងរចនាសម្ព័ន្ធនៃសមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អយ្យការ ព្រមទាំងគោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការនេះផងដែរ។

**ជំពូកទី២** : ការចោទប្រកាន់របស់អយ្យការ ៖ រៀបរាប់លម្អិតអំពីការចោទប្រកាន់របស់អយ្យការ ដែលសិក្សាទៅលើចំណុចដូចជា លក្ខខណ្ឌ នីតិវិធីនៃការចោទប្រកាន់តាមការបើកការស៊ើបសួរ និងអានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្រមទាំងសិក្សាទៅលើលក្ខខណ្ឌ នីតិវិធីនៃការចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងអានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចុងក្រោយគឺសិក្សាទៅលើលក្ខខណ្ឌ នីតិវិធីនៃការចោទប្រកាន់តាមរយៈកំណត់ហេតុបង្ហាញខ្លួនភ្លាម និងអានុភាពនៃការបង្ហាញខ្លួនភ្លាម។

**ជំពូកទី៣** : ការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ ៖ នៅក្នុងជំពូកនេះយើងខ្ញុំនឹងរៀបរាប់អំពីមូលហេតុលម្អិតនៃការមិនចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ ដែលមានដូចជា នត្ថិភាពនៃបទល្មើស មូលហេតុគតិយុត្ត ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ និងជម្រើសនៃការណែនាំ។ ក្រៅពីនេះក៏មានលម្អិតអំពីនីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ព្រមទាំងយន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញផងដែរ តាមរយៈការធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អំណាចអធិបញ្ញា និងតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៖ ការស្វែងរកចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ដែលកើតមានឡើង និងការវិភាគស្វែងរកដំណោះស្រាយដ៏សមរម្យ ដើម្បីចូលរួមកាត់បន្ថយនូវកង្វះខាតដែលបានកើតឡើង។

# ជំពូកទី១
# សញ្ញាណទូទៅនៃ
# ស្ថាប័នអយ្យការ

# ជំពូកទី១

# សញ្ញាណទូទៅនៃស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋដែលតំណាងឲ្យអង្គការនីតិប្រតិបត្តិ ដែលមាននៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ សម្រាប់ដំណើរការបណ្តឹងអាជ្ញា បណ្តឹងព្រហ្មទណ្ឌ ឬជាបណ្តឹងបរិហារ ដើម្បីឲ្យមានសកម្មភាពងាយស្រួលក្នុងការស្វែងរកយុត្តិធម៌ក្នុងសង្គមជាតិ។ ស្ថាប័នអយ្យការ ជាស្ថាប័នដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[1] បានសេចក្តីថា អង្គការអយ្យការមានសិទ្ធិក្នុងការបង្ក្រាបរាល់បទល្មើសទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាផលប្រយោជន៍ជាតិផងដែរ។ ស្ថាប័នអយ្យការ គឺជាអង្គឯករាជ្យដែលមិនស្ថិតក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ហើយសាលាជម្រះក្តីគ្មានអំណាចក្នុងការត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ស្ថាប័នអយ្យការ មិនមែនជាស្ថាប័នដែលទទួលបន្ទុកក្នុងការជម្រះក្តីដូចតុលាការឡើយ ប៉ុន្តែស្ថាប័នអយ្យការ គឺជាភាគីនៃរឿងក្តីព្រហ្មទណ្ឌ ដែលជាអ្នកតំណាងឲ្យផលប្រយោជន៍ទូទៅ។ ដូចនេះ ដើម្បីអាចបំពេញតួនាទីរបស់ខ្លួនក្នុងនាមជាភាគីនៃរឿងក្តីណាមួយ អយ្យការត្រូវមានអ្នកតំណាងរបស់ខ្លួននៅគ្រប់តុលាការជម្រះក្តី ដែលអ្នកតំណាងនោះគឺជាមន្ត្រីក្នុងស្ថាប័នអយ្យការ ដែលត្រូវបានគេហៅថា "តំណាងអយ្យការ"។

## ផ្នែកទី១ ៖ រចនាសម្ព័ន្ធរបស់ស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ ត្រូវបានដាក់ឲ្យនៅអមតុលាការគ្រប់ជាន់ថ្នាក់នៅក្នុងប្រទេសកម្ពុជា ដែលមានតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់។ តុលាការជាន់ខ្ពស់មានដូចជា សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ចំណែកតុលាការជាន់ទាបមានដូចជា សាសាដំបូងរាជធានី-ខេត្ត និងតុលាការយោធា។ ដូចនេះ អង្គការអយ្យការក៏បានបែងចែកជាពីរថ្នាក់ដែរគឺ អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់ ដែលមានមហាអយ្យការអមសាលាឧទ្ធរណ៍ និងមហាអយ្យការអមតុលាការកំពូល និងអង្គការអយ្យការជាន់ទាប ដែលមានអយ្យការអមសាលាដំបូងរាជធានី-ខេត្ត និងអយ្យការអមតុលាការយោធា។ ការបែងចែកស្ថាប័នអយ្យការជាច្រើនថ្នាក់បែបនេះ គឺដើម្បីឲ្យមានភាពយុត្តិធម៌នៅក្នុងសង្គម ព្រោះបើស្ថាប័នអយ្យការជាន់ទាបធ្វើខុស ឬមិនគោរពតាមច្បាប់ និងកាតព្វកិច្ចរបស់ខ្លួន ស្ថាប័នជាន់ខ្ពស់មានសិទ្ធិបញ្ជាទៅស្ថាប័នអយ្យការជាន់ទាប ឲ្យធ្វើការពិនិត្យទៅលើរឿងក្តីនោះឡើងវិញបាន។ ការបែងចែកស្ថាប័នអយ្យការនេះដែរ ក៏ដើម្បីផ្តល់ភាពងាយស្រួលនៅក្នុងការធ្វើការ និងដំណើរការរឿងក្តី ព្រោះស្ថាប័នថ្នាក់នីមួយៗ មានតួនាទី សិទ្ធិអំណាច និងភារកិច្ចផ្សេងៗពីគ្នាតាមការកំណត់

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤

ដោយច្បាប់តាមឋានៈពីខ្ពស់ទៅទាប ដែលគេហៅថា ( ឋានានុក្រម )។

**១. មហាអយ្យការអមតុលាការកំពូល**

នៅតុលាការកំពូល មានស្ថាប័នអយ្យការមួយដែលគេហៅថា ***មហាអយ្យការអមតុលាការកំពូល*** ។ មហាអយ្យការអមតុលាការកំពូល មានតំណាងអយ្យការដូចជា៖

- **អគ្គព្រះរាជអាជ្ញា**
- អគ្គព្រះរាជអាជ្ញារង និង
- ព្រះរាជអាជ្ញា។[2]

មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមតុលាការកំពូល។[3]

អគ្គព្រះរាជអាជ្ញាតុលាការកំពូល គឺជាប្រធានស្ថាប័នអយ្យការអមតុលាការកំពូល ជាអ្នកគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់។ នៅក្នុងមហាអយ្យការអមតុលាការកំពូលមាន**អគ្គព្រះរាជអាជ្ញាតែមួយរូបគត់ដែលជាប្រធានស្ថាប័ន**។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមក្នុងការសុំឲ្យមានការគោរពច្បាប់ នៅពេលដែលមានបណ្តឹងសារទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ។ អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល និងព្រះរាជអាជ្ញាអមតុលាការកំពូលអាចមានមួយរូប ឬច្រើនរូបទៅតាមសេចក្តីត្រូវការរបស់តុលាការកំពូល។

**២. មហាអយ្យការអមសាលាឧទ្ធរណ៍**

នៅសាលាឧទ្ធរណ៍ គឺមានស្ថាប័នអយ្យការមួយដែលគេហៅថា **មហាអយ្យការអមសាលាឧទ្ធរណ៍**។ មហាអយ្យការអមតុលាការឧទ្ធរណ៍ មានតំណាងអយ្យការដូចជា៖

- **អគ្គព្រះរាជអាជ្ញា**
- អគ្គព្រះរាជអាជ្ញារង និង

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣១

[3] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤, មាត្រា ៦៨

• ព្រះរាជអាជ្ញា។[4]

មហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាពដូចជា៖

• អគ្គព្រះរាជអាជ្ញា

• អគ្គព្រះរាជអាជ្ញារង

• ព្រះរាជអាជ្ញា

• ក្រឡាបញ្ជី និង

• មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាឧទ្ធរណ៍។[5]

មហាអយ្យការអមសាលាឧទ្ធរណ៍ គឺជាស្ថាប័នដែលនៅអមសាលាឧទ្ធរណ៍ ហើយនឹងបំពេញការងារនៅក្នុងសាលាឧទ្ធរណ៍នោះតែម្តង។នៅក្នុងមហាអយ្យការអមសាលាឧទ្ធរណ៍***អគ្គព្រះរាជអាជ្ញាជាប្រធានស្ថាប័នអយ្យការហើយមានតែមួយរូបតែប៉ុណ្ណោះ*** ចំណែកឯអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអាចមានច្រើនរូបទៅតាមតម្រូវការរបស់សាលាឧទ្ធរណ៍នោះ។ មហាអយ្យការអមសាលាឧទ្ធរណ៍ **ត្រូវដឹកនាំដោយអគ្គព្រះរាជអាជ្ញា** អមដោយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងការជួយសម្រួលដល់កិច្ចដំណើរក្នុងសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការចាត់តាំងអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងកិច្ចដំណើរការ និងអង្គជំនុំជម្រះផ្សេងៗ។ រាល់សេចក្តីសន្និដ្ឋាន ដែលបានធ្វើឡើងដោយអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវដាក់ឲ្យអគ្គព្រះរាជអាជ្ញាត្រួតពិនិត្យជាមុនសិនមុនពេលសវនាការ។ អគ្គព្រះរាជអាជ្ញា មានសិទ្ធធ្វើ **អធិបញ្ញាលើព្រះរាជអាជ្ញាអមសាលាដំបូង** ឲ្យធ្វើការចោទប្រកាន់បាន ឬចាត់ឲ្យចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានតាមការយល់ឃើញថាជាការគួរ ។[6]ម្យ៉ាងវិញទៀត អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិការកិច្ចទៅលើអង្គការអយ្យការទាំងឡាយ ដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[7] ព្រមទាំងឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ផងដែរ។

### ៣. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត គឺជាតុលាការជាន់ទាប ដែលមិនរាប់បញ្ចូលនូវតុលាការពិសេសណាមួយឡើយ។ អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត គឺជាស្ថាប័នមួយសម្រាប់ធ្វើការចោទ

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣៣ ។

[5] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤, មាត្រា ៤៩ ។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៩ ។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣៤ ។

ប្រកាន់រាល់រឿងក្តីដែលបានកើតមានឡើងនៅគ្រប់រាជធានី-ខេត្ត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នៅគ្រប់សាលាដំបូងរាជធានី-ខេត្ត គឺមានអយ្យការមួយដែលគេហៅថា "អយ្យការអមសាលាដំបូងរាជធានី-ខេត្ត" ។

**អង្គការអយ្យការអមតុលាការដំបូងមានតំណាងអយ្យការដូចជា៖**

- **ព្រះរាជអាជ្ញា និង**
- ព្រះរាជអាជ្ញារង។[8]

អយ្យការអមតុលាការដំបូងមានសមាសភាពដូចជា៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[9]

អយ្យការអមសាលាដំបូង មានឋានៈទាបជាងគេនៅក្នុងស្ថាប័នអយ្យការ។ អយ្យការអមសាលាដំបូង **មានព្រះរាជអាជ្ញាតែមួយរូបប៉ុណ្ណោះជាប្រធានស្ថាប័ន** និងមានព្រះរាជអាជ្ញារងជាច្រើនរូបទៀត។ ព្រះរាជអាជ្ញាជាប្រធានក្នុងការដឹកនាំកិច្ចដំណើរការប្រព្រឹត្តទៅរបស់អង្គការអយ្យអមសាលាដំបូង។ ព្រះរាជអាជ្ញា ជាភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ បានសេចក្តីថា ព្រះរាជអាជ្ញាជាអ្នកធ្វើការចោទប្រកាន់លើរឿងក្តីទាំងឡាយណាជារឿងព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញារង ជាសេនាធិការស្ថិតក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ហើយបានប្រើប្រាស់អំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ។[10]

### ៤. អយ្យការអមតុលាការយោធា

តុលាការយោធា គឺជាតុលាការមួយដែលដោះស្រាយករណីបទល្មើសយោធាតែប៉ុណ្ណោះ ហើយបទល្មើសយោធាដែលត្រូវយកទៅដោះស្រាយនៅក្នុងតុលាការយោធានោះគឺ៖

- បទល្មើសបង្កឡើងដោយយោធិន (កំពុងស្ថិតក្នុងជួរកងទ័ព)
- បទល្មើសមិនគោរពវិន័យកងទ័ព
- បទល្មើសលួច ទ្រព្យសម្បត្តិ ឬសម្ភារៈយោធា ។ល។

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា៣៦ ។

[9] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤, មាត្រា ២៩ ។

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣៨ ។

នៅក្នុងអយ្យការអមតុលាការយោធា មានព្រះរាជអាជ្ញាតែមួយរូបប៉ុណ្ណោះជាប្រធានស្ថាប័ន និងមានព្រះរាជអាជ្ញារងជាច្រើនរូបទៀតតាមតម្រូវការរបស់តុលាការ។

## ផ្នែកទី២ ៖ សមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អយ្យការ

អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ និងធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើ ការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ។[11] ចៅក្រមអយ្យការមានដូចជា៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។[12]

### ១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងករណីមានបទល្មើសមួយកើតមានឡើង តាមរយៈការស្រាវជ្រាវលើបទល្មើសមួយអាចនឹងធ្វើឡើងជាច្រើនទីកន្លែងតាមការកំណត់ដែលពាក់ព័ន្ធនឹងបទល្មើសនោះមានជាអាទិ៍ ទីកន្លែងប្រព្រឹត្តបទល្មើស ទីកន្លែងជនសង្ស័យរស់នៅ និងទីកន្លែងដែលចាប់ខ្លួនជនសង្ស័យ។

សមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញាមានដូចជា៖

- ព្រះរាជអាជ្ញានាទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ព្រះរាជអាជ្ញានាលំនៅឋានរបស់ជនសង្ស័យបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនជនដែលត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។[13]

### ២. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានតួនាទីយ៉ាងសកម្មក្នុងចំណាត់ការរឿងក្ដីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ហើយដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តក្នុងស្រុក ក្នុងការស៊ើបអង្កេតបទលល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាព នៃការស៊ើបអង្កេត ពិនិត្យមើលការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ និង ការបំពេញតួនាទីផ្សេងទៀត ដោយតំណាងឲ្យផលប្រយោជន៍សាធារណៈ។តួនាទីរបស់អង្គការអយ្យការ ឬ ស្ថាប័នអយ្យការដោយ

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៧ ។
[12] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៨ ។
[13] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣៩ ។

ផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ១៣១ថ្មី បានផ្តល់អំណាចផ្តាច់មុខទៅឲ្យអង្គការអយ្យការសម្រាប់ធ្វើបណ្តឹងអាជ្ញា។ អង្គការអយ្យការ ជាម្ចាស់នៃបណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ បានន័យថាមានតែស្ថាប័នអយ្យការទេ ដែលអាចធ្វើការបណ្តឹងអាជ្ញាទាំងឡាយឲ្យដំណើរការបាន។ និយាយម្យ៉ាងទៀតគឺថា (ជាគោលការណ៍) ម្ចាស់នៃបណ្តឹងអាជ្ញានេះ គឺមានសិទ្ធិក្នុងការប្រើប្រាស់នូវជម្រើសនៃការចោទប្រកាន់របស់ខ្លួនបាន។ ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តនូវតួនាទីបំពេញបន្ថែមទៀតទៅឲ្យអង្គការអយ្យការ ដោយមាត្រា ៤ បានចែងថា បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការ ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ អយ្យការធ្វើការអនុវត្តទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយជាស្ថាពរ។[14] ម្យ៉ាងទៀតមាត្រា ២៧ ក៏បានបញ្ជាក់បន្ថែមពីតួនាទីរបស់អង្គការអយ្យការមួយចំនួនដូចជា៖

- អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់
- អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ
- យកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

### ៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវឈរលើគោលការណ៍សំខាន់ៗដូចជា៖

- ជំហរការងាររបស់ព្រះរាជអាជ្ញា ត្រូវអនុវត្តដោយមិនលំអៀង និងជៀសវាងនូវការប្រកាន់និន្នាការនយោបាយ វប្បធម៌ ភេទ សាសនា និងការរើសអើងគ្រប់ទម្រង់។
- ព្រះរាជអាជ្ញាការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនមានភាពលំអៀង ព្រមទាំងប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះបីជាស្ថានការណ៍នោះមានប្រយោជន៍ ឬមិនមានប្រយោជន៍ដល់សង្គមក៏ដោយ។
- រក្សាការសម្ងាត់នៃរឿងក្តី លើកលែងតែដើម្បីតែការបំពេញភារកិច្ច ឬដើម្បីតម្រូវការ របស់តុលាការ ដើម្បីបញ្ជាក់អំពីភាពយុត្តិធម៌។
- ព្រះរាជអាជ្ញាត្រូវពិនិត្យមើលទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានផលប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេ និងបញ្ជាក់ពីសិទ្ធិដល់ជនរងគ្រោះឲ្យស្របតាមសេចក្តីប្រកាសពីគោលការណ៍យុត្តធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ និងការរំលោភអំណាច។
- ព្រះរាជអាជ្ញាត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញា ចំពោះមន្ត្រីសាធារណៈដែលបាន

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៩៧ កថាខណ្ឌទី១ ។

ប្រព្រឹត្តបទល្មើស ជាពិសេសអំពើពុករលួយការរំលោភអំណាច ការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ។[15]

ព្រះរាជអាជ្ញា ត្រូវរក្សារឿងក្តីដែលមាននៅក្នុងសមត្ថកិច្ចជាការសម្ងាត់ ដើម្បីបញ្ជាក់ពីភាពយុត្តិធម៌នៃតុលាការ។ ម្យ៉ាងវិញទៀត ការពារផលប្រយោជន៍របស់ជនរងគ្រោះ និងត្រូវធានាថាមិនមានការរំលោភអំណាចផ្សេងៗដែលនាំឲ្យជាក្តីបារម្ភរបស់ជនរងគ្រោះ។

## ៤. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានសិទ្ធិអំណាចជាគោលការណ៍ក្នុងការទទួលបានគ្រប់ព័ត៌មានទាំងអស់ ដែលជាប្រយោជន៍ក្នុងបណ្តឹង និងទៅតាមច្បាប់ដែលបានកំណត់។ ព្រះរាជអាជ្ញាក្នុងដំណាក់កាលចោទប្រកាន់ សិទ្ធិអំណាចអាចធ្វើការបែងចែកជា៣គឺ អំណាចលើនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

- **អំណាចលើមន្ត្រីនគរបាលយុត្តិធម៌**[16]**៖** ព្រះរាជអាជ្ញាគឺជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានអនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ នឹងត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចធ្វើការចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេត និងធ្វើការការណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយរៀបចំជំនួសសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី។ជាមួយគ្នានេះផងដែរព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចទៅលើអង្គភាពនគរបាលយុត្តិធម៌ ដើម្បីត្រួតពិនិត្យពីកិច្ចដំណើរការលើសំណុំរឿង ។
- **អំណាចក្នុងការស៊ើបអង្កេត៖** ដើម្បីធ្វើការចោទប្រកាន់ថាជាបទល្មើសចំពោះអំពើណាមួយបាន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតដោយពិនិត្យមើលទៅលើអង្គហេតុដែលបានកើតឡើង និងត្រូវកំណត់ច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការធ្វើការចោទប្រកាន់។ ការស៊ើបអង្កេតនេះព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការបើកការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមមានជាអាទិ៍ដូចជាការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ការធ្វើកំណត់ហេតុ ការធ្វើកោសល្យវិច័យ និងការស្តាប់ការសន្ទនា។

[15] គោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយអង្គការសហប្រជាជាតិ ឆ្នាំ១៩៩០ ប្រទេសគុយបា ទីក្រុងហាវ៉ាណា។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣៧ ។

- **អំណាចក្នុងការធ្វើការចោទប្រកាន់៖** ក្នុងដំណាក់កាលចោទប្រកាន់ ព្រះរាជអាជ្ញាមានសមត្ថកិច្ច និង ទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿង ដោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការ បើទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ឬក៏ធ្វើការចោទប្រកាន់ ដែលហៅថាគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់។

## ផ្នែកទី៣ ៖ គោលការណ៍សំខាន់ៗរបស់ស្ថាប័នអយ្យការ

### ១. គោលការណ៍អវិភាគ

គោលការណ៍អវិភាគ គឺជាគោលការណ៍មួយដែលកំណត់ឲ្យព្រះរាជអាជ្ញាមានភារកិច្ចបំពេញការងារក្នុង អង្គការអយ្យការអមសាលាជម្រះក្តីណាមួយ ត្រូវមានកាតព្វកិច្ចរួមក្នុងមុខងារនោះ និងអាចជំនួសគ្នាទៅវិញទៅ មកបានដូចជាក្នុងករណីមានធុរៈដូចជាជាប់បេសកកម្មទៅក្រៅប្រទេស ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវ បានចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន។ តាមគោលការណ៍នេះតំណាងអយ្យការ អាចបន្ត ការងារគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[17] ករណីដែលព្រះរាជអាជ្ញា ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងភាពទំនេរ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្តីទីជំនួសបាន ដើម្បីធានាបាននូវ ដំណើរការល្អរបស់អយ្យការអមសាលាដំបូង រហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ។

### ២. គោលការណ៍ឯកភាព (គោលការណ៍ឋានានុក្រម)

គោលការណ៍នេះ គឺជាគោលការណ៍មួយដែលឲ្យតំណាងអយ្យការទាំងអស់អនុវត្តការងាររបស់ខ្លួន ដោយតម្រូវស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។

- **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាឋានានុក្រមខ្ពស់ជាងគេនៃអង្គការអយ្យការ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃស្ថាប័នអយ្យការ អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ទៅអង្គការ អយ្យការគ្រប់ជាន់ថ្នាក់មានដូចជា អង្គការមហាអយ្យការអមតុលាការកំពូល អង្គការមហាអយ្យការអមសាលា ឧទ្ធរណ៍ និងអង្គការអយ្យការអមសាលាដំបូង។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួង យុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។

- **អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល៖** អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃ មហាអយ្យការអមតុលាការកំពូល។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន ។

[17] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤, មាត្រា៧៥ កថាខណ្ឌទី២ ។

- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** គឺជានាយបានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវស្ថិតក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយបានានុក្រមរបស់ខ្លួន។
- **ព្រះរាជអាជ្ញាអមសាលាដំបូង** គឺជានាយបានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការនៅក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយបានានុក្រមរបស់ខ្លួន ។[18]

### ៣. គោលការណ៍ឯករាជ្យ

ស្ថាប័នអយ្យការ ដែលនៅអមនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមានឯករាជ្យភាពពីអំណាចតុលាការដោយមិនស្ថិតក្រោមអំណាចសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ និងជាស្ថាប័នឯករាជ្យមិនចំណុះក្រោមសាលាជម្រះក្តីណាមួយទេ។ តុលាការ មិនអាចធ្វើអធិបញ្ញាលើតំណាងអយ្យការទេ ហើយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មិនអាចធ្វើការត្រួតពិនិត្យលើកិច្ចដំណើរការរបស់ព្រះរាជអាជ្ញាបានឡើយ ព្រោះវាគឺជាការបំពានគោលការណ៍នៃការបែងចែកមុខងារ និងអំណាចរបស់ស្ថាប័នទាំងបី។ ព្រះរាជអាជ្ញា មានសេរីភាពក្នុងការនិយាយបានដោយសេរីទៅលើអង្គហេតុនៃការសាកសួរដេញដោល ដើម្បីស្វែងរកភស្តុតាងមកធ្វើការដាក់បន្ទុក ក្នុងការចោទប្រកាន់ទៅលើជនជាប់ចោទនៅពេលមានសវនាការ។ នៅក្នុងករណី ដែលមានការប្រព្រឹត្តកំហុសឆ្គងកើតឡើងក្នុងពេលបំពេញមុខងាររបស់ព្រះរាជអាជ្ញា ដូចពាក្យមួយឃ្លាបានពោលថា( ***បកាជាទាសី សំដីដោយសេរី*** ) សាលាជម្រះក្តីមិនអាចធ្វើការស្តីបន្ទោស ឬសេចក្តីសម្រេចរបស់ខ្លួនទៅលើព្រះរាជអាជ្ញាបានឡើយ។ ប៉ុន្តែសាលាជម្រះក្តីអាចធ្វើការលើកសំណើរទៅកាន់នាយបានានុក្រមរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើចំណាត់ការអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញានោះបាន។[19]

### ៤. គោលការណ៍មិនអាចប្តឹងជំទាស់

អង្គការអយ្យការ ដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលស្ថិតក្នុងតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មិនត្រូវបានពាក់ព័ន្ធទៅការប្តឹងជំទាស់ទេ ព្រោះថាព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ ហើយព្រះរាជអាជ្ញាមិនតំណាងឲ្យខ្លួនឯងនោះទេ បើទោះបីជាព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធនឹងសាច់ញាតិ ឬមានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយ។ ម្យ៉ាងវិញទៀត បើទោះបីជាមានការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយ មិនមែនបានន័យថាបុគ្គលនោះជាជនត្រូវចោទនោះដែរ។

### ៥. គោលការណ៍នៃការមិនទទួលខុសត្រូវ

[18] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤, មាត្រា៧៥ កថាខណ្ឌទី១ ។
[19] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤, មាត្រា៧៥ កថាខណ្ឌទី៣ ។

ព្រះរាជអាជ្ញា ក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ ក្នុងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណាដែលគិតថាជាបទល្មើសព្រហ្មទណ្ឌ។ ***ចៅក្រមអយ្យការ ជាអ្នកតំណាងឲ្យផលប្រយោជន៍សាធារណៈ ដូច្នេះបើខ្លួនចាញ់រឿងក្តីព្រហ្មទណ្ឌនោះ ក៏មិនមាននរណាម្នាក់អាចទាមទារឲ្យទទួលខុសត្រូវបានទេ*** ។[20] ក្នុងករណីខ្លះ អង្គហេតុដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់អាចនឹងត្រូវច្រានចោលដោយចៅក្រមស៊ើបសួរ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ឬដោយចៅក្រមជំនុំជម្រះ ប្រសិនបើអង្គហេតុនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬមិនមានភស្តុតាងក្នុងការដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីកំណត់ធាតុផ្សំនៃបទល្មើស។ ប្រសិនបើមានករណីនេះកើតមានឡើង ព្រះរាជអាជ្ញាមិនអាចត្រូវទទួលខុសត្រូវរាល់ការខូតខាតទាំងឡាយ ដែលកើតចេញពីការសម្រេចចិត្តរបស់ខ្លួនទៅលើរឿងក្តីនោះឡើយ ជាពិសេសគឺជនត្រូវចោទ ឬជនជាប់ចោទនៅក្នុងសំណុំរឿងនោះ។ ប៉ុន្តែ ព្រះរាជអាជ្ញាអាចនឹងទទួលខុសត្រូវព្រហ្មទណ្ឌ ពេលដែលខ្លួនបានប្រព្រឹត្តកំហុសជាបទល្មើសព្រហ្មទណ្ឌដែលកើតចេញពីឆន្ទៈទុច្ចរិតនៅពេលបំពេញមុខងាររបស់ខ្លួន។ បើមានករណីព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុស ដែលជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ នាំឲ្យព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។

[20] សាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងលោកស្រីចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៦, ទំព័រទី៩ ។

# ជំពូកទី២
# ការចោទប្រកាន់របស់អយ្យការ

# ជំពូកទី២

# ការចោទប្រកាន់របស់អយ្យការ នាពេលបច្ចុប្បន្ន

មុននឹងឈានទៅរកការចោទប្រកាន់ ទៅលើជនណាម្នាក់ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ លុះត្រាណាតែមានការទទួលបណ្តឹងទាមទារពីជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ ឬទទួលបានរបាយការណ៍មកពីមន្ត្រីនគរបាលយុត្តិធម៌។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ឬបណ្តឹងផ្សេងទៀតតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ជនរងគ្រោះ ជនអនាមិក ឬតាមបណ្តាញសារព័ត៌មានក្តី ស្ថាប័នអយ្យការត្រូវតែថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងនោះ។ ប៉ុន្តែ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានភ្លាមៗនោះទេ គឺព្រះរាជអាជ្ញាត្រូវធ្វើការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែមជាមុនសិន[21]។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាមុនសម្រេចធ្វើការចោទប្រកាន់ ត្រូវពិនិត្យលើកត្តាចំបងសំខាន់ៗមួយចំនួនដូចជា ៖

- កំណត់ថាតើអំពើដែលបានប្រព្រឹត្ត ជាបទល្មើសព្រហ្មទណ្ឌដែរ ឬទេ?
- តើអំពើដែលបានប្រព្រឹត្តនោះមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ដែរ ឬទេ?
- ការចោទប្រកាន់ ត្រូវឲ្យសមស្របនឹងអំពើដែលជនសង្ស័យបានប្រព្រឹត្តដែរឬទេ ?

ក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ បន្ទាប់ពីបានកសាងសំណុំរឿងឡើង ដោយបានធ្វើការស៊ើបអង្កេតយ៉ាងត្រឹមត្រូវរួចមក ព្រះរាជអាជ្ញាត្រូវសម្រេចថា គួរធ្វើការចោទប្រកាន់ដែរឬទេ។ ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ដែលត្រូវអនុវត្តលើរូបវន្តបុគ្គល និងនីតិបុគ្គល ដោយឈរលើគោលការណ៍ឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ឬស្ថានភាពឯទៀតឡើយ។ ការចោទប្រកាន់ គឺជាចំណាត់ការនីតិវិធី ដែលព្រះរាជអាជ្ញាមានអានុភាព និងសមត្ថកិច្ចពេញលេញទៅលើយុត្តាធិការស៊ើបសួរ និងជំនុំជម្រះ។ ការចោទប្រកាន់នេះដែរ គឺទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលនៃបទល្មើស ដែលមានរយៈពេលកំណត់ដូចជា ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៥ឆ្នាំ ចំពោះបទមជ្ឈិម និង១ឆ្នាំចំពោះបទលហុ។[22]យោងលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៤៣ បានចែងថាការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើឡើងតាម ការបើកការស៊ើបសួរ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងតាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

## ផ្នែកទី១ ៖ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាការធ្វើបណ្តឹងរបស់ព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរមកលើអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ម្យ៉ាងវិញទៀត ផ្អែកលើការស្រាវជ្រាវលើអង្គហេតុរបស់ចៅក្រមស៊ើបសួរ គឺមានលក្ខណៈខុសពីការស្រាវជ្រាវ ដែលធ្វើឡើងដោយព្រះរាជអាជ្ញាដោយសារ

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤០ ។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ១០ ។

មូលហេតុថា ព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវអំពីព័ត៌មាន និងភស្តុតាងទាំងឡាយណា ដើម្បីធ្វើការកំណត់ឲ្យឃើញពីការពិតអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌក្នុងការចោទប្រកាន់។ ដោយឡែកសំណុំរឿងដែលត្រូវបានបញ្ជូនឲ្យមកចៅក្រមស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរធ្វើការស៊ើបសួរនោះ ចៅក្រមស៊ើបសួរត្រូវតែបំពេញភារកិច្ចរបស់ខ្លួនធ្វើការស្រាវជ្រាវ ដើម្បីស្វែងរកឲ្យឃើញពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់។ បន្ថែមពីនេះទៅទៀត ចៅក្រមស៊ើបសួរនឹងត្រូវធ្វើការស្រាវជ្រាវនូវរាល់គ្រប់ទិន្នន័យនៃព័ត៌មានទាំងអស់ដែលរួមមាន ភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[23]។

### ១. លក្ខខណ្ឌដែលធ្វើឲ្យមានចំណាត់ការក្នុងការបើកការស៊ើបសួរ

ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានធ្វើការកំណត់អំពីលក្ខខណ្ឌមួយចំនួន ដើម្បីបើកការស៊ើបសួរស្របតាមនីតិវិធីក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។លក្ខខណ្ឌដែលព្រះរាជអាជ្ញា ត្រូវគោរពមុនសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបើកការស៊ើបសួរនោះ ត្រូវមើលលើប្រភេទនៃបទល្មើសជាមុនសិន។ ដោយយោងតាម មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការកំណត់ពីប្រភេទនៃបទល្មើសមុននឹងធ្វើការបើកការស៊ើបសួររួមមាន៖ បទឧក្រិដ្ឋ និងបទមជ្ឈិម។

**ករណីបទឧក្រិដ្ឋ៖** កាលណាមានបទល្មើសឧក្រិដ្ឋកើតឡើង ព្រះរាជអាជ្ញាចាំបាច់ត្រូវតែបើកការស៊ើបសួរ[24]រាល់គ្រប់បទល្មើសទាំងឡាយណាដែលជាប្រភេទបទឧក្រិដ្ឋត្រូវតែមានបើកការស៊ើបសួរ ដោយមូលហេតុថាបទល្មើសឧក្រិដ្ឋ គឺជាប្រភេទបទល្មើសទាំងឡាយណាដែលមានអប្បបរមានៃទោសក្នុងពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ និងអតិបរមាជាទោសដាក់ពន្ធនាគារអស់មួយជីវិត[25]។ ដោយសារមូលហេតុនៃការកម្រិតទោសទៅលើជនល្មើសមានលក្ខណៈធ្ងន់ធ្ងរតម្រូវឲ្យមានការធ្វើការស្រាវជ្រាវឲ្យមានភាពល្អិតល្អន់ និងជាក់លាក់មុននឹងសម្រេចនាំខ្លួនជនល្មើសទៅធ្វើការជំនុំជម្រះនៅមុខតុលាការ ដើម្បីចៀសវាងការជំនុំជម្រះដោយមានការធ្វេសប្រហែស ឬមានការភាន់ច្រលំដែលនាំឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ជន ដែលត្រូវបានធ្វើការចោទប្រកាន់។ ម្យ៉ាងវិញទៀត ដើម្បីធានាដល់ការអនុវត្តការកាត់ក្តីប្រកបដោយយុត្តិធម៌សម្រាប់ភាគីទាំងសងខាង។ បទឧក្រិដ្ឋនេះទៀតសោតត្រូវធ្វើការស៊ើបសួរជាមុន ដែលស្ថិតក្រោមចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរទាំងភស្តុតាងក្នុងការដាក់បន្ទុក និងភស្តុតាងក្នុងការដោះបន្ទុក ព្រោះដើម្បីធ្វើការត្រួតពិនិត្យដោយជាក់លាក់ និងស្វែងឲ្យដឹងពីការពិត និងបង្ហាញច្បាស់ពីការជំនុំជម្រះរបស់ប្រព័ន្ធយុត្តាធិការប្រកបដោយភាពយុត្តិធម៌។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ១២៧ ។

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៤ ។

[25] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៤៦ ។

**ករណីបទមជ្ឈិម៖** ដោយយោងតាមមាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាក៏អាចអនុវត្តនីតិវិធីនេះបានដែរក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញា អាចធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបាន។[26] ដោយមូលហេតុបទមជ្ឈិម ជាប្រភេទបទល្មើសមានការដាក់ទោសឲ្យជាប់ពន្ធនាគារមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬស្មើនឹង ៥ឆ្នាំ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[27] ស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេចថាគួរបើកការស៊ើបសួរ ឬមិនបើកការស៊ើបសួរ ដោយធ្វើការពិនិត្យឲ្យច្បាស់អំពីស្ថានភាពនៃបទល្មើស។ ប៉ុន្តែមានស្ថានភាពមួយចំនួន ដែលបទមជ្ឈិមត្រូវតែបើកការស៊ើបសួរដូចជា បើជនត្រូវចោទបានប្រព្រឹត្តបទល្មើសនោះតែមិនមានភស្តុតាងគ្រប់គ្រាន់ មិនស្គាល់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ និងករណីដែលមានជនល្មើសចូលរួមប្រព្រឹត្តច្រើន។ បានសេចក្តីថាសំណុំរឿងមិនទាន់មានព័ត៌មានគ្រប់គ្រាន់ ឬឯកសារគ្រប់គ្រាន់ដើម្បីធ្វើការជំនុំជម្រះបាន ដូច្នេះហើយ ព្រះរាជអាជ្ញានឹងត្រូវធ្វើការចោទប្រកាន់ទៅតាមនីតិវិធីក្នុងការស៊ើបសួរ។

### ២. នីតិវិធី និងទម្រង់នៃការបើកការស៊ើបសួរ

ជាក់ស្តែងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាដែលបានទទួលសំណុំរឿងពីការដាក់ពាក្យបណ្តឹងរបស់ដើមបណ្តឹង ឬតាមរយៈពាក្យបណ្តឹងដែលបញ្ជូនសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌។ ដូច្នេះព្រះរាជអាជ្ញាមុននឹងសម្រេចបើកការស៊ើបសួរត្រូវធ្វើការវាយតម្លៃ និងវិនិច្ឆ័យឲ្យបានច្បាស់លាស់ទៅលើសំណុំរឿង តាមប្រភពនៃការបញ្ជូននីមួយៗ។

#### ២.១. ការបើកការស៊ើបសួរដោយទទួលពាក្យបណ្តឹងបញ្ជូនមក

ពាក្យបណ្តឹង អាចធ្វើឡើងដោយផ្ទាល់ពីដើមបណ្តឹង ដើម្បីឲ្យព្រះរាជអាជ្ញាងាយស្រួលចំណាត់ការចំពោះពាក្យបណ្តឹងទាំងនោះ។ នៅពេលព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹងដោយផ្ទាល់ហើយ នោះព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើចំណាត់ការថ្លឹងថ្លែង ក្នុងការសម្រេចធ្វើការចោទប្រកាន់ទៅតាមនីតិវិធីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលអង្គហេតុនោះជាបទល្មើស។ ក្នុងការថ្លឹងថ្លែង និងការស្រាវជ្រាវដែលត្រូវបានធ្វើឡើងតាមរយៈការដាក់ពាក្យសុំទៅមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការបើកការស៊ើបអង្កេតបឋម ឬការកោះហៅ ដើមបណ្តឹង ជនសង្ស័យ សាក្សី[28] ដើម្បីធ្វើការសាកសួរ និងស្តាប់ចម្លើយផ្ទាល់។ នៅពេលដែលបញ្ចប់ការបើកការស៊ើបអង្កេត និងស្រាវជ្រាវរួចហើយ ក្នុងករណីដែលអង្គហេតុនោះជាបទល្មើស និងបានបំពេញទៅតាមលក្ខខណ្ឌនៃការបើកការស៊ើបសួរដូចដែលបានបកស្រាយខាងលើ ព្រះរាជអាជ្ញា នឹងសម្រេចធ្វើការបើកការស៊ើបសួរតាមរយៈដីកា

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៥ ។
[27] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា៤៧ ។
[28] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ១១ ។

សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

**២.២. ការបើកការស៊ើបសួរដោយទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌**

ការបើកការស៊ើបសួរអាចធ្វើទៅបានផងដែរ ក្រោយពីបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលបានពាក្យប្តឹងពីជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ ដែលទាមទារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើការបើកការស៊ើបអង្កេតជាបឋមចំពោះរាល់បណ្តឹងដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួល ឬពេលដែលមានបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុណាមួយ រួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ លើសពីនេះទៅទៀត ចំពោះករណីដែលមានបទល្មើសជាក់ស្តែងកើតមានឡើង មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិធ្វើការចាប់ខ្លួន ឬឃាត់ខ្លួនទៅលើជនសង្ស័យ និងបញ្ជូនខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា។ ចំពោះនីតិវិធីនៃការអនុវត្តលើចំណាត់ការនៃរឿងក្តី ដែលត្រូវបានបញ្ជូនមកពីមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងក្រោមរូបភាពដូចខាងក្រោម៖

**សំណុំរឿងដែលមានជនសង្ស័យ** គឺជាសំណុំរឿងទាំងឡាយណាដែលត្រូវបានចាប់ជនសង្ស័យនោះបាន ឬក៏មានការឃាត់ខ្លួនជនសង្ស័យដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលបាននាំខ្លួនជនសង្ស័យមកអនុវត្តនីតិវិធីនៅចំពោះមុខព្រះរាជអាជ្ញា ក្រោយពេលនៃការឃាត់ខ្លួនត្រូវបានកន្លងផុត ហើយព្រះរាជអាជ្ញាអាចបើកការសាកសួរចម្លើយ និងពិនិត្យទៅលើរាល់សំណុំរឿងទៅលើជនសង្ស័យផងដែរ។ ព្រះរាជអាជ្ញាពិនិត្យទៅលើតែអង្គហេតុ និងភស្តុតាង ដែលជារបាយការណ៍សំយោគនៃសំណុំរឿងមន្ត្រីនគរបាលយុត្តិធម៌ បានធ្វើការសន្និដ្ឋានក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ។ ក្នុងករណីនេះ ប្រសិនបើការពិនិត្យលើសំណុំរឿងឃើញថាជាបទល្មើស និងបានបំពេញលក្ខខណ្ឌក្នុងការបើកការស៊ើបសួរ នាំឲ្យព្រះរាជអាជ្ញានឹងចេញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជាងនេះទៅទៀត ព្រះរាជអាជ្ញាអាចធ្វើការសន្និដ្ឋានសុំឲ្យចៅក្រមស៊ើបសួរ ដាក់ជននោះស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសន្និដ្ឋានសុំឲ្យជននោះស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នបានផងដែរ។

**សំណុំរឿងដែលគ្មានជនសង្ស័យ** គឺសំដៅដល់សំណុំរឿងទាំងឡាយណា ដែលបានបញ្ជូនមកពីមន្ត្រីនគរបាលយុត្តិធម៌ដែលជនសង្ស័យពុំត្រូវបានឃាត់ខ្លួនទេ ហើយបញ្ជូនមកកាន់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាដែលបានទទួលសំណុំរឿងនេះ នឹងធ្វើការថ្លឹងថ្លែងទៅលើអង្គហេតុ ដោយមានការពិនិត្យយ៉ាងល្អិតល្អន់ទៅលើភស្តុតាង និងរបាយការណ៍សំយោគដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការកោះហៅភាគីដែលពាក់ព័ន្ធដូចជា ដើមបណ្តឹង សាក្សី ជនសង្ស័យដើម្បីធ្វើការសាកសួរ និងស្តាប់ចម្លើយ។ ក្រោយពីបានធ្វើការសាកសួររួច ក្នុងករណីដែលអង្គហេតុនៃសំណុំរឿងគឺជាបទល្មើសនោះ ហើយបានបំពេញលក្ខខណ្ឌ ដែលតម្រូវឲ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ និងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយកំណត់ឈ្មោះជនត្រូវចោទ ឬអញ្ញាតជនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

### ២.៣. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យធ្វើការស៊ើបសួរ

ក្នុងខណៈពេលដែលមានការសម្រេចពីការចោទប្រកាន់តាមរយៈការស៊ើបសួរពីព្រះរាជអាជ្ញានោះ គឺតម្រូវឲ្យព្រះរាជអាជ្ញាចាំបាច់ត្រូវធ្វើការរៀបចំលិខិតនីតិវិធី គឺដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យធ្វើការស៊ើបសួរ ទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីបំពេញមុខងាររបស់ខ្លួនក្នុងការស៊ើបសួរ។ ម្យ៉ាងវិញទៀតនោះ ព្រះរាជអាជ្ញាត្រូវបំពេញលិខិតទម្រង់នៃដីកានោះឲ្យបានច្បាស់លាស់ផងដែរ ដោយស្របតាមនីតិវិធីនៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យធ្វើការស៊ើបសួរនោះរួមមាន៖

- សេចក្តីសង្ខេបអង្គហេតុ
- ការកំណត់ឈ្មោះនៃបទល្មើស
- ការបង្ហាញអត្ថបទដែលបានកំណត់ឲ្យបានច្បាស់លាស់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវបានធ្វើការស៊ើបសួរ ក្នុងករណីដែលបានធ្វើការកំណត់រួច។

ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីលក្ខណៈដាច់ខាត ដែលតម្រូវឲ្យព្រះរាជអាជ្ញាត្រូវតែគោរព បានសេចក្តីថា ប្រសិនបើចំណុចនៃទម្រង់ការនៃដីកាសន្និដ្ឋាននេះមិនបានបំពេញនោះ នាំឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនឹងត្រូវចាត់ទុកជាមោឃៈ[29] ដោយមូលហេតុថាសភាស៊ើបសួរបានទទួលបានពាក្យសុំមោឃភាពពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។[30]

### ៣. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ក្រោយពីបានសម្រេចធ្វើការចោទប្រកាន់ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា បានធ្វើឲ្យដីកានេះបង្កើតឲ្យមានអានុភាពដូចជា ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកកិច្ចស៊ើបសួរ និងការកំណត់ពីដែនសមត្ថកិច្ចលើការស៊ើបសួរ។

**ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស៖** ថិរវេលានៃអាជ្ញាយុកាលរបស់បទល្មើស គឺត្រូវគិតពីការចាប់ផ្តើមដែលបានប្រព្រឹត្តបទល្មើស។ អាជ្ញាយុកាល ត្រូវបានផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ[31] មានសេចក្តីថាគ្រប់កិច្ចចោទប្រកាន់ទាំងអស់ពីសំណាក់ព្រះរាជអាជ្ញា ទោះជាតាមរយៈការបង្ហាញខ្លួនភ្លាម ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬការបើកការស៊ើបសួរនោះទេ ព្រោះសញ្ញាណនៃការចោទប្រកាន់មួយដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស។ ចំពោះគ្រប់កិច្ចនៃការស៊ើបសួរ សំដៅទៅរាល់កិច្ចដែល

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៤ ។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៥៣ ។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ១១ ។

មានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរ កិច្ចទាំងនេះ មានអានុភាពកាត់ផ្ដាច់អាជ្ញាយុកាលនៃបណ្ដឹងផងដែរ។

**ការផ្ទេរសមត្ថកិច្ចទៅកាន់ចៅក្រមស៊ើបសួរដើម្បីឲ្យធ្វើការស៊ើបសួរ៖** គ្មានកិច្ចចោទប្រកាន់ណាពីសំណាក់ព្រះរាជអាជ្ញាទេ ប្រសិនបើគ្មានការធ្វើការស៊ើបសួរជាមុននោះ តែលើកលែងការដាក់ឲ្យមានចលនាបណ្ដឹងអាជ្ញាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរនឹងត្រូវមោឃភាព បើសិនជាគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ការប្ដឹងមោឃភាព គឺជាសកម្មភាពទាំងឡាយដែលបានប្ដឹងទៅកាន់សភាស៊ើបសួរ ក្នុងករណីដែលយល់ឃើញខុសនីតិវិធីកិច្ចស៊ើបសួរ ហើយមានតែសភាស៊ើបសួរទេដែលមានសមត្ថកិច្ចពិនិត្យមើលមោឃភាពនៃលិខិតណាមួយនៃនីតិវិធីព្រហ្មទណ្ឌ។[32]

**ការកំណត់ដែនសមត្ថកិច្ចលើការស៊ើបសួរ៖** ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ជាគោលការណ៍ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបាន លុះត្រាតែមានដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចស៊ើបសួរត្រឹមតែអង្គហេតុដែលចង្អុលបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ ។ ប្រសិនបើបទល្មើសបានលេចចេញឡើងនូវអង្គហេតុថ្មីនោះ ចៅក្រមស៊ើបសួរ មានភារកិច្ចត្រូវជូនព័ត៌មានដែលទាក់ទងទៅនឹងអង្គហេតុនេះទៅកាន់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរទៅអង្គហេតុថ្មីដែលខ្លួនបានរកឃើញនោះតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា ។ កិច្ចស៊ើបសួរអាចត្រូវមោឃភាពបាន ក្នុងករណីដែលកិច្ចស៊ើបសួរនេះត្រូវបានបំពាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែ មានករណីខ្លះមិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះទេ ដូចជាប្រសិនបើមានអង្គហេតុថ្មីបានរកឃើញ ហើយមានស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលបានកំណត់ជាស្រេចក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង។ ចៅក្រមស៊ើបសួរ មានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។[33]

## ផ្នែកទី២ ៖ ការចោទប្រកាន់តាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដើម្បីចាប់ផ្ដើមនីតិវិធីក្នុងកិច្ចបញ្ជូនរឿងឲ្យជំនុំជម្រះផ្ទាល់បាន លុះត្រាតែព្រះរាជអាជ្ញាសម្រេចចេញដីកាមួយជាមុនសិន ដែលយើងហៅថា ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។[34] ការចោទប្រកាន់តាមរយៈដីកា

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៥៣ ។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ១២៥ ។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៦៨ ។

បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីដែលព្រះរាជអាជ្ញាបញ្ជាឲ្យជនជាប់ចោទ ធ្វើការចូលមកបង្ហាញខ្លួននៅចំពោះមុខសាលាជម្រះក្តីជាន់ទាប (សាលាដំបូង)។[35] ព្រះរាជអាជ្ញាអាចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនៅសាលាដំបូងតែម្តង ដោយមិនចាំបាច់ឆ្លងកាត់ទៅតាមនីតិវិធីចៅក្រមស៊ើបសួរឡើយ។ កិច្ចដំណើរការនីតិវិធីជំនុំជម្រះផ្ទាល់នេះ ត្រូវទាមទារឲ្យគោរពតាមលក្ខខណ្ឌមួយចំនួន ដើម្បីធ្វើឲ្យដីកានេះមានអានុភាពដល់ចំណាត់ការរបស់យុត្តាធិការជំនុំជម្រះ។

### ១. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ដោយប្រើនីតិវិធីនៃការបញ្ជូនរឿងទៅឲ្យជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែចេញដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដែលដីកានេះទាមទារឲ្យគោរពទៅតាមលក្ខខណ្ឌមួយចំនួន។ លក្ខខណ្ឌនេះ គឺសំដៅទៅលើលក្ខខណ្ឌនៃបទល្មើសរបស់ជនល្មើសត្រូវបានបំពេញ និងលក្ខណៈនៃសាវតាជាតិរបស់ជនល្មើសដែលត្រូវបានបំពេញ។

#### ១.១. លក្ខខណ្ឌនៃបទល្មើស

ចំពោះលក្ខខណ្ឌនៃបទល្មើស ត្រូវកំណត់ទៅតាមប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ដែលមានការបែងចែកជា៣ធំៗគឺ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ម្យ៉ាងវិញទៀត ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានធ្វើការបកស្រាយ បង្ហាញពីធាតុផ្សំនៃបទល្មើសបទលហុ និងបទមជ្ឈិម ដែលបានផ្តល់អំណាចឲ្យព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ដោយប្រើប្រាស់នីតិវិធីបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់ មានន័យថាមានតែបទល្មើសមជ្ឈិម និងបទលហុទេដែលអាចប្រើនីតិវិធីនេះសម្រាប់ការចោទប្រកាន់បាន។ ព្រះរាជអាជ្ញា ដែលជាអ្នកកាន់សំណុំរឿងផ្ទាល់ត្រូវមានភាពជឿជាក់ និងយល់ច្បាស់លាស់ថាសំណុំរឿង មានលក្ខណៈគ្រប់គ្រាន់ដែលអាចធ្វើការជំនុំជម្រះផ្ទាល់បាន។

**លក្ខខណ្ឌចំពោះបទលហុ៖** បទលហុ គឺសំដៅទៅលើបទល្មើសទាំងឡាយណា ដែលត្រូវបានទទួលទោសដាក់ពន្ធនាគាររយៈពេលអតិបរមានៃទោសស្មើ ឬមិនលើសពី៦ថ្ងៃ ឬទោសពិន័យជាប្រាក់តែប៉ុណ្ណោះ។[36] នៅពេលអង្គហេតុដែលមានស្ថានទោសជាបទលហុ នាំឲ្យព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង[37] ដោយមូលហេតុថា បទលហុជាប្រភេទបទល្មើសដែលមានលក្ខណៈផ្តន្ទាទោសស្រាល និងតូចតាច។ ផ្ទុយទៅវិញ បើត្រូវរងចោទប្រកាន់ដោយប្រើនីតិវិធីផ្សេងៗដូចជា ការចូលបង្ហាញខ្លួនភ្លាម ឬការបើកការស៊ើបសួរ វាធ្វើឲ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនជាប់ចោទយ៉ាងធ្ងន់ធ្ងរ ព្រោះតាមនីតិវិធីការចូល

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៦ ។

[36] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៤៨ ។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៩ ។

បង្ហាញខ្លួន និងការបើកស៊ើបសួរ ទាមទារឲ្យមានការឃុំខ្លួនជនជាប់ចោទរហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

**លក្ខខណ្ឌចំពោះបទមជ្ឈិមៈ** បទមជ្ឈិម ជាប្រភេទបទល្មើសមានការដាក់ទោសឲ្យជាប់ពន្ធនាគារមានរយៈពេលលើសពី៦ថ្ងៃ និងក្រោម ឬស្មើនឹង៥ឆ្នាំ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[38] បទមជ្ឈិមអាចចោទប្រកាន់តាមទម្រង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[39] ប៉ុន្តែមិនមែនគ្រប់បទមជ្ឈិមទាំងអស់សុទ្ធតែត្រូវធ្វើនីតិវិធីចោទប្រកាន់បែបនេះទេ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ពុំបានធ្វើការបញ្ជាក់ច្បាស់ពីប្រភេទបទមជ្ឈិមបែបណា ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាធ្វើការជំនុំជម្រះផ្ទាល់បាន ទោះបីជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែងក៏ដោយ វាជាការផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាជាអ្នកថ្លឹងថ្លែងក្នុងការសម្រេច ដោយយោងទៅតាមស្ថានភាពអង្គហេតុនៃបទល្មើស ។ ប្រសិនបើ ព្រះរាជអាជ្ញាបានពិនិត្យឃើញថាមានភស្តុតាងគ្រប់គ្រាន់ តុលាការនឹងធ្វើការជំនុំជម្រះសម្រេចសេចក្តីលើបទល្មើសបាន ដោយព្រះរាជអាជ្ញានឹងប្រើនីតិវិធីក្នុងការចោទប្រកាន់នេះ តែក៏អាចធ្វើការបើកការស៊ើបសួរ ឬការចូលបង្ហាញខ្លួនបានផងដែរ ដោយហេតុថាមានករណីបទមជ្ឈិមមួយចំនួន ត្រូវឲ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងៗផងដែរ។ ជាក់ស្តែងប្រសិនបើមានករណីស្ថានភាពនៃបទមជ្ឈិមដែលភាពស្មុគស្មាញក្នុងការដោះស្រាយ និងមានស្ថានភាពដោយឡែកដូចជាមិនទាន់រកឃើញភស្តុតាងគ្រប់គ្រាន់ មិនទាន់ស្គាល់អត្តសញ្ញាណជនល្មើសជាដើម គឺតម្រូវទាមទារឲ្យមានការបើកការស៊ើបអង្កេត ដើម្បីស្វែងរកភស្តុតាងឲ្យបានគ្រប់គ្រាន់ និងជាក់លាក់ស្របតាមនីតិវិធី។

### ១.២. អត្តសញ្ញាណរបស់ជនល្មើស

ព្រះរាជអាជ្ញា ចាំបាច់ត្រូវរកឲ្យឃើញអត្តសញ្ញាណរបស់ជនល្មើសនោះ ព្រោះវាជាមូលហេតុចាំបាច់សម្រាប់ធ្វើការកំណត់បង្ហាញពីលក្ខខណ្ឌមួយក្នុងការធ្វើបណ្តឹងអាជ្ញា មានគោលបំណងក្នុងការស្វែងរកអត្ថិភាពនៃបទល្មើស បូករួមទាំងការផ្តន្ទាទោសទៅលើជនល្មើសផងដែរ។ នីតិវិធីនៃការបញ្ជូនរឿងឲ្យជំនុំជម្រះផ្ទាល់នេះចាំបាច់ធ្វើការទាមទារកំណត់ពីអត្តសញ្ញាណរបស់ជនល្មើសដោយខានមិនបាន ដោយហេតុថា ប្រសិនបើជនល្មើសមិនបានស្ថិតក្នុងភាពស្គាល់អត្តសញ្ញាណទេនោះ នាំឲ្យដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់មិនអាចប្រព្រឹត្តបានទេ។ ម្យ៉ាងវិញទៀត ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការទទួលស្គាល់វិសាលភាពនៃបណ្តឹងចំពោះជនជាប់ចោទ មានន័យថាតុលាការនឹងធ្វើការជំនុំជម្រះទៅលើជនទាំងឡាយណា ដែលមានក្នុងពាក្យបណ្តឹងតែប៉ុណ្ណោះ។ ដូច្នេះ ការស្គាល់នូវអត្តសញ្ញាណរបស់ជនល្មើសគឺជាកត្តាចាំបាច់ និងជាលក្ខខណ្ឌដែលមិនអាចខ្វះបានឡើយ។

[38] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៤៧ ។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៥ ។

## ២. នីតិវិធី និងទម្រង់នៃដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់

នីតិវិធីនៃការបញ្ជូនរឿងជំនុំជម្រះផ្ទាល់ គឺសំដៅទៅលើនីតិវិធីមួយ ដែលមិនចាំបាច់ធ្វើការឆ្លងកាត់នូវដំណាក់កាលស៊ើបសួរនោះទេ ដែលជាហេតុនាំឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ភ្លាម តាមរយៈពាក្យបណ្តឹង និងលក្ខខណ្ឌនៃការបញ្ជូនរឿងជំនុំជម្រះផ្ទាល់។ បន្ទាប់មក ក៏បញ្ជូនសំណុំរឿងនេះតាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់ទៅយុត្តាធិការដើម្បីធ្វើការជំនុំជម្រះផ្ទាល់ និងចេញដីកាកោះហៅជនជាប់ចោទ ចូលមកសវនាការធ្វើការជំនុំជម្រះ។ ម្យ៉ាងវិញទៀត ការចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់នេះ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែបំពេញលក្ខខណ្ឌឲ្យស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលបានបង្ហាញក្នុងគោលបំណងធានាឲ្យបានដីកាកោះហៅមានសុពលភាព។

ព្រះរាជអាជ្ញា នឹងអនុវត្តដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឡើង ដោយមានទម្រង់ច្បាស់លាស់ និងជាក់លាក់ដើម្បីងាយស្រួលដល់ចៅក្រមជំនុំជម្រះពិនិត្យ និងវិនិច្ឆ័យថា បទល្មើសដែលចៅក្រមធ្វើការចោទប្រកាន់នោះត្រឹមត្រូវតាមនីតិវិធីច្បាប់ដែរឬទេ។ ដោយយោងតាម ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៦ បានធ្វើការកំណត់ពីទម្រង់នៃដីកាកោះហៅជំនុំជម្រះផ្ទាល់ ដែលជាមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងកំណត់នូវផលប្រយោជន៍ដ៏សំខាន់ក្នុងកិច្ចជំនុំជម្រះ ហើយទម្រង់នៃដីកាកោះហៅជំនុំជម្រះផ្ទាល់រួមមាន៖

- អត្តសញ្ញាណរបស់ជនជាប់ចោទ
- សេចក្តីសង្ខេបរបស់អង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

## ៣. លក្ខខណ្ឌដែលនាំឲ្យមានសុពលភាពលើដីកាកោះហៅជំនុំជម្រះផ្ទាល់

តាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ក្នុងការធានាជនជាប់ចោទ តម្រូវឲ្យមានរយៈពេលសមស្របដើម្បីឲ្យជនជាប់ចោទបានត្រៀមលក្ខណៈឡើងសវនាការ។ ការកំណត់នេះ មានរយៈពេលខុសៗគ្នាដែលវាអាស្រ័យទៅលើស្ថានភាព ឬទីតាំងដែលជនជាប់ចោទមានវត្តមានស្នាក់នៅ ដើម្បីធានាថាជនជាប់ចោទមានរយៈពេលសមរម្យក្នុងការរៀបចំខ្លួនសម្រាប់ត្រៀមឡើងសវនាការ។ យោងតាម មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការកំណត់រយៈពេលនៃការចេញដីកាកោះហៅជនជាប់ចោទដូចតទៅ៖

- ១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ក្នុងករណីជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅឲ្យចូលបង្ហាញខ្លួន នោះតុលាការនឹងបង្គាប់ឲ្យចេញដីកាកោះជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់។ ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ និងយល់ព្រមយ៉ាងជាក់លាក់ឲ្យជំនុំជម្រះភ្លាមៗ តុលាការអាចពិនិត្យមើលរឿង ប៉ុន្តែបើសិនជនជាប់ចោទមិនព្រមឲ្យជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឲ្យលើករឿងនេះទៅជំនុំជម្រះនៅពេលសវនាការពេលក្រោយទៀត។[40]

### ៤. អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជាដីកាដែលចេញដោយព្រះរាជអាជ្ញា ក្នុងការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌ។ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ នាំឲ្យបង្កើតបានអានុភាពដូចជា ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ច និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុនិងជនជាប់ចោទ ។

❖ **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖** ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ជានីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលជាហេតុនាំឲ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។ ប្រសិនបើគ្មានការកំណត់បែបនេះទេ អាចមានករណីខ្លះនៅពេលដែលបណ្តឹងបញ្ជូនទៅតុលាការ តែត្រូវផុតអាជ្ញាយុកាលដែលនាំឲ្យជនល្មើសត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនទៅវិញ។ បណ្តឹងអាជ្ញាមិនអាចធ្វើបានជាដាច់ខាត កាលបើផុតអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់ខាងព្រហ្មទណ្ឌ ហើយអាជ្ញាយុកាលនឹងត្រូវបានផ្តាច់ កាលណាមានកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាកើតឡើង។[41] អាជ្ញាយុកាលនៃបទល្មើស ត្រូវគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ឬគិតចាប់ពីពេលចាប់ផ្តើមកិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ យោងតាម មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អាជ្ញាយុកាលនៃបទល្មើសនេះគឺ៖

- ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង
- ១ ឆ្នាំ ចំពោះបទលហុ។

❖ **ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖** ជាទូទៅតុលាការមានសមត្ថកិច្ចជំនុំជម្រះបាន លុះត្រាតែមានបណ្តឹងមកខ្លួនតែប៉ុណ្ណោះ។ ក្នុងរឿងក្តីព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលពាក្យបណ្តឹងដោយដីកាបញ្ជូនទៅតុលាការជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា។[42] ខុសពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរឲ្យបើកកិច្ចស៊ើបសួរ តែដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ត្រូវបានប្រគល់សំណុំ

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៤៩១ ។
[41] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ១១ ។
[42] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២៩១ ។

រឿងទៅឲ្យតុលាការធ្វើការជំនុំជម្រះតែម្តង ដោយពុំឆ្លងកាត់ ដំណាក់កាលចៅក្រមស៊ើបសួរនោះឡើយ។

❖ **ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ៖** តុលាការអាចសម្រេចសេចក្តីតែទៅលើអំពើណាដែលមានបង្ហាញនៅក្នុងដីកាកោះហៅបញ្ជូនទៅជនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ តុលាការ នឹងធ្វើការជំនុំជម្រះតែទៅលើអង្គហេតុ និងបុគ្គល ដែលបានកំណត់ក្នុងកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យមានការបង្ហាញខ្លួន។ តុលាការ ពុំអាចធ្វើការជំនុំជម្រះទៅលើអង្គហេតុ និងបុគ្គលផ្សេងទៀត ដែលពុំមានក្នុងកំណត់ហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នោះឡើយ។ តែជួនកាលក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថាអង្គហេតុ ដែលបានប្តឹងនោះបង្កើតបានជាបទឧក្រិដ្ឋ តុលាការនឹងបង្គាប់ឲ្យបង្វិលសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរវិញ (មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧)។

## ផ្នែកទី៣ ៖ ការចោទប្រកាន់តាមរយៈកំណត់ហេតុបង្ហាញខ្លួនភ្លាម

ការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ជានីតិវិធីក្នុងការចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញា ដែលអាចបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមចំពោះមុខតុលាការជាន់ដំបូង និងត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ នីតិវិធីនេះបញ្ញត្តឡើងដើម្បីជម្រុញដល់ដំណើរការរឿងក្តីឲ្យបានឆាប់រហ័សជៀសវាងការកកស្ទះនូវសំណុំរឿង។

### ១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម

ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះព្រះរាជអាជ្ញាអាចធ្វើការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការមានជាអាទិ៍៖

❖ **បទល្មើសត្រូវតែជាបទល្មើសជាក់ស្តែង៖** បើពិនិត្យមើលមាត្រា៤៧ដដែលត្រង់ចំណុចទី១ នេះច្បាប់ប្រើពាក្យថា បទល្មើសជាបទល្មើសជាក់ស្តែង ហើយបានចង្អុលបង្ហាញទៅមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ដែលបានចែងថា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ជាបទល្មើសដែលកំពុងប្រព្រឹត្ត ទើបប្រព្រឹត្តរួចភ្លាម ឬកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រភីង បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើស។ និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ដែលបានចែងថា គឺចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ ទោះបីជាស្ថិតនៅក្រៅករណីដែលមានចែងក្នុងមាត្រា៨៦(និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះសុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារ

នគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

❖ **ការផ្តន្ទាទោសៈ** បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច មួយឆ្នាំ និងយ៉ាងច្រើន ប្រាំឆ្នាំ។ ចិរវេលានៃការផ្តន្ទាទោសនេះ យើងត្រូវមើលទៅលើអតិបរមានៃទោសដែលបានចែងក្នុងច្បាប់។ បទមជ្ឈិម មានការផ្តន្ទាទោសជាអប្បបរមា១(មួយ)ឆ្នាំ និងអតិបរមា ៥(ប្រាំ)ឆ្នាំ។

❖ **ជនជាប់ចោទជានីតិជនៈ** មានន័យថាការដែលជនជាប់ចោទត្រូវដល់នីតិភាព ដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលការជំនុំជម្រះមានភាពឆាប់រហ័សជាងនីតិវិធីដទៃទៀត ហើយក្នុងនីតិវិធីនេះ តុលាការអាចសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្នចំពោះជនជាប់ចោទផងដែរ។ ដូចនេះ ដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិការពារខ្លួនរបស់អនីតិជន ទើបច្បាប់តម្រូវឲ្យអនុវត្តនីតិវិធីនេះចំពោះតែនីតិជនប៉ុណ្ណោះ។

❖ **រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបានៈ** ព្រះរាជអាជ្ញាត្រូវតែមានភស្តុតាង ឬមូលហេតុធ្ងន់ល្មមក្នុងការដាក់បន្ទុកដើម្បីធ្វើការចោទប្រកាន់ ប្រសិនបើគ្មានបន្ទុកភស្តុតាងគ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានទេ។ បើគ្មានភស្តុតាង ឬហេតុផលរឹងមាំសម្រាប់ដាក់បន្ទុកជនជាប់ចោទទេ នេះអាចជាឱកាសដល់ជនជាប់ចោទក្នុងករណី ដែលមានសេចក្តីសម្រេចស្ថាពរឲ្យជនជាប់ចោទរួចខ្លួន ជាហេតុនាំឲ្យព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ជាថ្មីបាន ដោយសារតែគោលការណ៍អាជ្ញាអស់ជំនុំ។

## ២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលមានលក្ខណៈខុសប្លែកពីនីតិវិធីទាំងពីរខាងលើ ដោយហេតុថានីតិវិធីនេះមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់។ យោងតាមបញ្ញត្តនៃមាត្រា៤៨ និងមាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចកំណត់បានពីនីតិវិធីនៃការបង្ហាញខ្លួនភ្លាមជាពីរដំណាក់កាលគឺ នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា និងនីតិវិធីក្នុងដំណាក់កាលយុត្តាធិការ។

### ២.១ នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា

បន្ទាប់ពីបានពិនិត្យមើលអង្គហេតុដែលជាពាក្យប្តឹង ឬពាក្យបរិហារដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក បើត្រូវជ្រើសរើសនីតិវិធីនៃការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម នោះព្រះរាជអាជ្ញាត្រូវៈ

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលត្រូវបញ្ជូនមក
- ឲ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ និងបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

ទម្រង់ការខាងលើត្រូវតែចុះក្នុងកំណត់ហេតុ បើមិនដូច្នោះទេ ត្រូវចាត់ទុកជាមោឃៈ។ ក្រោយពីធ្វើ

កំណត់ហេតុរួចហើយ ជនជាប់ចោទត្រូវបង្ខាំងទុកដោយកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។

**២.២ នីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ**

ពេលទទួលបានកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម តុលាការ ត្រូវធ្វើការផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានចោទប្រកាន់នោះ ហើយត្រូវប្រាប់ដល់ជនជាប់ចោទពីរយៈពេលសម្រាប់រៀបចំដើម្បីការពារខ្លួន។ បើជនជាប់ចោទយល់ថា ខ្លួនពុំទាន់មានពេលគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន អាចធ្វើការសុំរយៈពេលបន្ថែម ឬក្នុងករណីដែលតុលាការយល់ឃើញថាអង្គហេតុនោះនៅមិនទាន់អាចជំនុំជម្រះបាន តុលាការអាចលើកសវនាការនៅពេលក្រោយបាន។ ក្នុងករណីនេះ តុលាការ អាចធ្វើការបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នបាន ដោយចេញសាលក្រមមានបញ្ជាក់ពីសំអាងហេតុដែលជាមូលហេតុចាំបាច់នៃមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ជាអាទិ៍៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាប់សង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គ្រាន់តែមានអានុភាពទៅលើជនជាប់ចោទប៉ុណ្ណោះ ជាហេតុនាំឲ្យតុលាការត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដើម្បីធ្វើការបញ្ជាឲ្យដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទ។[43]

គិតចាប់ពីថ្ងៃចូលបង្ហាញខ្លួនមុខតុលាការ តុលាការត្រូវប្រកាសសាលក្រមលើអង្គសេចក្តីក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍។ បើពុំនោះទេ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ហើយជនជាប់ចោទត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ ព្រោះវិធានការនៃការឃុំខ្លួនបណ្តោះអាសន្ន ជាការប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពរបស់បុគ្គលដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។

**៣. អានុភាពនៃការបង្ហាញខ្លួនភ្លាម**

ប្រសិនបើព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម នោះអានុភាពនឹងកើត

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២២០ ។

ឡើងតាមកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាមដូចជា ការផ្អាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចទៅតុលាការ និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ។

**ការផ្អាច់អាជ្ញាយុកាលនៃបទល្មើស៖** អាជ្ញាយុកាល ត្រូវផ្អាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ចំពោះកំណត់ហេតុស្ដីពីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ក៏ជាកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែរ ដែលមានអានុភាពនាំឲ្យមានការផ្អាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្ដើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល ។

**ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖** តុលាការ ទទួលបានបណ្ដឹងតាមរយៈកំណត់ហេតុបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដែលធ្វើដោយព្រះរាជអាជ្ញា។ សមត្ថកិច្ចត្រូវបានផ្ទេរមកយុត្តាធិការជំនុំជម្រះតែម្ដង ដោយពុំឆ្លងកាត់យុត្តាធិការស៊ើបសួរឡើយ។

**ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ៖** កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានកំណត់ពីអង្គហេតុ និងកំណត់ពីបុគ្គលដែលព្រះរាជអាជ្ញាចង់ធ្វើការចោទប្រកាន់។ តុលាការ អាចធ្វើការជំនុំជម្រះតែទៅលើអង្គហេតុ និងបុគ្គលដែលបានកំណត់ក្នុងកំណត់ហេតុស្ដីអំពីការបង្គាប់ឲ្យមានបង្ហាញខ្លួនតែប៉ុណ្ណោះ។[44] តុលាការ ពុំអាចធ្វើការជំនុំជម្រះទៅលើអង្គហេតុ និងបុគ្គលផ្សេងដែលពុំមានកំណត់ក្នុងកំណត់ហេតុនោះឡើយ។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ៣៤៩

# ជំពូកទី៣

# ការតម្កល់រឿងទុកឥតចាត់ការ
# របស់អយ្យការ

# ជំពូកទី៣

# ការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ នាពេលបច្ចុប្បន្ន

សម្រាប់ការចោទប្រកាន់លើរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញា គឺអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ដែលបានសេចក្តីថាគ្រប់រឿងក្តីព្រហ្មទណ្ឌទាំងអស់ គឺព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ដោយមិនមានការលើកលែងឡើយ[45]។ ក្រោយពីមានការវិវត្តនៃបរិបទសង្គមឥតឈប់ឈរមក ***កម្ពុជាក៏ទទួលយកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧*** ។

ក្នុងបញ្ញត្តនៃមាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យប្តឹងបរិហារដែលខ្លួនទទួលដោយផ្ទាល់ ឬមន្ត្រីនរគបានយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចថាតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម។ តាមរយៈអត្ថន័យនៃមាត្រា៤០ នេះ ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការចោទប្រកាន់ដូចដែលបានធ្វើការរៀបរាប់ក្នុងជំពូកទី២ ហើយព្រះរាជអាជ្ញា ក៏មានសិទ្ធិសម្រេចតាមឆន្ទានុសិទ្ធរបស់ខ្លួនក្នុងការមិនចោទប្រកាន់ ដោយមានការត្រិះរិះពិចារណាត្រឹមត្រូវ សមហេតុផល និងថ្លឹងថ្លែងតាមស្ថានភាពជាក់ស្តែង ទោះបីអំពើនោះមានចែងនៅក្នុងបញ្ញត្តច្បាប់កំណត់ក៏ដោយ។ ព្រះរាជអាជ្ញាត្រូវគិតពីសណ្តាប់ធ្នាប់សង្គមថា តើការចោទប្រកាន់នាំឲ្យមានភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈកម្រិតណា ? ។

## ផ្នែកទី១ ៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ជាទូទៅព្រះរាជអាជ្ញា ត្រូវបានច្បាប់ទទួលស្គាល់ថាជាម្ចាស់បណ្តឹង ក្នុងគោលដៅចោទប្រកាន់ជនល្មើសព្រហ្មទណ្ឌ ។ ជាដំបូងព្រះរាជអាជ្ញាអាចទទួលបណ្តឹងដោយពាក្យប្តឹង ឬពាក្យបណ្តឹងបរិហាដោយផ្ទាល់ ឬតាមរយៈមន្ត្រីនរគបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាតែងតែប្រកាន់ភ្ជាប់នូវតួនាទីរបស់ខ្លួន ក្នុងការធានានូវសណ្តាប់ធ្នាប់សាធារណៈ ដូច្នេះ នៅពេលដែលព្រះរាជអាជ្ញាទទួលបានពាក្យបណ្តឹងដែលបញ្ជាក់ថាមានបទល្មើស ព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងទៅលើពាក្យបណ្តឹងនោះថាគួរធ្វើការចោទប្រកាន់ ឬមិនគួរធ្វើការចោទប្រកាន់។

មុនពេលធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតជាបឋម ឬធ្វើសេចក្តីបង្គាប់ ឲ្យមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវបន្ថែមជាមុនសិន។ ក្នុងករណីតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយអំពីស្ថានភាព និងកាលៈទេសៈ

[45] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣, មាត្រា៥៩ ។

ទាំងឡាយនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើស។ ក្នុងនាមជាអ្នកការពារសណ្តាប់ធ្នាប់ និងការពារផលប្រយោជន៍ទូទៅ ព្រមទាំងជាអ្នកសម្របសម្រួលក្នុងសង្គម តំណាងអយ្យការត្រូវបានប្រគល់នូវសិទ្ធិអំណាចពិសេស ដោយអាចសម្រេចដោយឆន្ទានុសិទ្ធិក្នុងការមិនចោទប្រកាន់លើរឿងក្តីព្រហ្មទណ្ឌ។ នេះគឺជាសិទ្ធិអំណាច ដែលអាចប្រើគោលការណ៍កាលានុវត្តភាព បានសេចក្តីថា បើបទល្មើសជាបទល្មើសមជ្ឈិមតូចតាច ហើយគ្មានព្យសនកម្ម ឬមានព្យសនកម្មតិចតួចបំផុត តំណាងអយ្យការអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។

ទោះបីជាព្រះរាជអាជ្ញាសម្រេចធ្វើការតម្កល់រឿងទុកឥតចាត់ការដោយឆន្ទានុសិទ្ធក៏ដោយ ក៏ការសម្រេចមិនចោទប្រកាន់នេះ គឺធ្វើឡើងដោយផ្អែកលើមូលដ្ឋានគ្រឹះដែលសមស្របមួយចំនួនមានដូចជា នត្ថិភាពនៃបទល្មើស មូលហេតុគិតយុត្តិ និងការចោទប្រកាន់ដែលមិនផ្តល់ផលប្រយោជន៍ផងដែរ។

### ១. នត្ថិភាពនៃបទល្មើស

រាល់បទល្មើស ដែលកើតមានឡើងហើយបន្សល់នូវព្យសនកម្ម មិនមែនសុទ្ធតែបទល្មើសព្រហ្មទណ្ឌនោះទេ។ ហើយអំពើទាំងនោះមិនប្រាកដថាត្រូវតែបានផ្តន្ទាទោសតាមច្បាប់នោះឡើយ មានន័យថា លុះត្រាតែមានចែងក្នុងអត្ថបទច្បាប់ថាអំពើនោះជាបទល្មើស ទើបអាចធ្វើការចោទប្រកាន់បាន។ ដូច្នេះហើយ នត្ថិភាពគឺសំដៅលើអវត្តមាននៃបទល្មើស និងធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់។

#### ១.១. អវត្តមាននៃបទល្មើស

នៅពេលដែលព្រះរាជអាជ្ញាកំពុងថ្លឹងថ្លែងពីបទល្មើស ដែលបណ្តឹងនោះខ្លួនទទួលបានដោយផ្ទាល់ ឬជាបណ្តឹងដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធ៌មចប់សព្វគ្រប់ ព្រមទាំងបានបើកការស៊ើបអង្កេត ស្រាវជ្រាវរួចហើយ តែបណ្តឹងនោះមិនមានវត្តមាននៃបណ្តឹងនោះទេ ព្រះរាជអាជ្ញាមានសិទ្ធិសម្រេចមិនធ្វើការចោទប្រកាន់។ អវត្តមាននៃបទល្មើស គឺសំដៅលើបទល្មើសដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ បណ្តឹងទាំងនោះ អាចជាបណ្តឹងរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម ឬវិវាទរដ្ឋបាលដែលតុលាការមិនអាចផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌបាន។

#### ១.២. ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់

បន្ទាប់ពីបានទទួលពាក្យបណ្តឹង ឬពាក្យប្តឹងបរិហា ហើយព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋម ឬស៊ើបអង្កេតស្រាវជ្រាវបន្ថែមដើម្បីស្វែងរកនូវធាតុផ្សំនៃបទល្មើស។ ធាតុផ្សំនៃបទល្មើសមានបីគឺ៖

- **ធាតុផ្សំនីត្យានុកូល៖** គឺជាធាតុផ្សំទាក់ទងនឹងច្បាប់។ ក្នុងករណីអំពើមួយបានកើតមានឡើង ហើយយើងអាចចាត់ទុកថានោះគឺជាបទល្មើសព្រហ្មទណ្ឌបាន លុះត្រាតែអំពើនោះ មានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៣ បានចែងថាអំពើលួចគឺជាបទល្មើសព្រហ្មទណ្ឌ។

- **ធាតុផ្សំសត្យានុម័តះ** ឬធាតុផ្សំសម្ភារៈ គឺជាអង្គហេតុ ឬជាហេតុការណ៍ទាំងឡាយណាដែលបង្កឲ្យកើតមាននូវអាកប្បកិរិយាណាមួយ ដែលត្រូវបានកំណត់នៅក្នុងអត្ថបទច្បាប់ ដែលបញ្ជាក់ថាជាបទល្មើស ។ អង្គហេតុទាំងនោះមានច្រើនណាស់ អាចជាអំពើសកម្ម និងជាអំពើអសកម្ម អំពើកើតឡើងភ្លាមៗ ឬអូសបន្លាយ អំពើកើតឡើងម្តងម្កាល់ ឬជាទម្លាប់ជាអាទិ៍។
- **ធាតុផ្សំអត្តនោម័តះ** ជាផ្នែកខាងក្នុងនៃបទល្មើស។ គឺជាឆន្ទៈជាចេតនាឬអចេតនា ដែលជាអកប្បកិរិយាផ្លូវចិត្តរបស់អ្នកប្រព្រឹត្តចំពោះអំពើបង្កគ្រោះថ្នាក់។

ក្នុងករណីដែលអវត្តមាននៃធាតុផ្សំនៃបទល្មើសណាមួយ ព្រះរាជអាជ្ញាគ្មានអំណាចក្នុងការបើកការចោទប្រកាន់ឡើយ ព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### ២. មូលហេតុគតិយុត្ត

ដូចយើងបានដឹងរួចមកហើយថា ព្រះរាជអាជ្ញាអាចប្រើប្រាស់នូវគោលការណ៍កាលានុវត្តភាព ឬជម្រើសនៃការចោទប្រកាន់[46] (មាត្រា៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩) ដែលគោលការណ៍ណនេះអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ចំណែកឯ ក្រមនីតិវីធីព្រហ្មទណ្ឌឆ្នាំ២០០៧ មិនបានបញ្ញត្តអំពីមូលហេតុគតិយុត្តណាខ្លះ ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបាននោះឡើយ ដែលក្រមនេះបានបញ្ញាត្តតែករណីនៃការរលត់នៃបណ្តឹងអាជ្ញា និងមូលហេតុគតិយុត្តផ្សេងៗទៀតតែប៉ុណ្ណោះ។

#### ២.១. ការរលត់នៃបណ្តឹងអាជ្ញា

កាលណាបណ្តឹងអាជ្ញា ត្រូវបានផុតរលត់ ហើយការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។ បានសេចក្តីថា បើមានមូលហេតុណាមួយដែលនាំឲ្យផុតរលត់នៃបណ្តឹងអាជ្ញាបានកើតឡើង គឺត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ ទោះក្នុងករណីដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់រួចហើយក៏ដោយ ក៏នីតិវិធីនៅគ្រប់ដំណាក់ត្រូវតែបញ្ចប់។ មូលហេតុដែលនាំឲ្យមានការរលត់នៃបណ្តឹងអាជ្ញាមានដូចជាៈ មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាការណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ[47]។

ក្រៅពីមូលហេតុគតិយុត្តខាងលើ ក៏មានមូលហេតុគតិយុត្តផ្សេងៗទៀត ដែលនាំឲ្យបណ្តឹងអាជ្ញាផុតរលត់ផងដែរ កាលណាច្បាប់ដោយឡែកបានចែងជាក់លាក់។ មូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញាមានដូចជាៈ ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹង ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យ

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា៧ កថាខណ្ឌទី២ ។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា៧ កថាខណ្ឌទី១ ។

សម្របសម្រួល[48]។

**ក. មរណភាពនៃជនល្មើស**

ចំណុចទី១ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងថា បណ្ដឹងអាជ្ញាត្រូវបានរលត់ ប្រសិនបើជនល្មើសបានទទួលមរណភាពទៅហើយ។ សំដៅលើមរណភាពនៃបុគ្គលដែលត្រូវបានចាត់ទុកថាជាជនល្មើស ឬសង្ស័យថាបានប្រព្រឹត្តដែលអាចក្លាយជាជនល្មើស ឬជាជនត្រូវចោទ ដែលកំពុងស្ថិតក្នុងនីតិវិធីណាមួយរបស់តុលាការ។ បើជនល្មើសទទួលមរណភាពហើយ ជននោះមិនអាចក្លាយជាប្រធាននៃនីតិវិធីដែលអាចទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចបានទៀតនោះទេ។ ម្យ៉ាងទៀតចំពោះគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវតែចំពោះអំពើរបស់ខ្លួនតែប៉ុណ្ណោះ។[49] បានសេចក្ដីថា ពុំមានបុគ្គលណាអាចទទួលទោសចំពោះជនល្មើសបានឡើយ ដូច្នេះបើជនល្មើសទទួលមរណភាពហើយ គឺមិនមាននរណាអាចទទួលខុសត្រូវព្រហ្មទណ្ឌជំនួសទៀតនោះដែរ។ ក្រមព្រហ្មទណ្ឌ សម្រាប់ដាក់ទោសលើជនទាំងឡាយដែលប្រព្រឹត្តខុសនឹងច្បាប់ ដើម្បីឲ្យជននោះបានកែប្រែ និងចូលចុះក្នុងសង្គមវិញ ព្រមទាំងឲ្យមហាជនមានការខ្លាចរអាក្នុងការប្រព្រឹត្តល្មើស ដែលនេះមិនមែនជាការសងសឹកឡើយ។ ចំណែកឯច្បាប់នៅក្នុងប្រទេសកម្ពុជាយើងទៀតសោត ក៏ពុំមានការដាក់ទោសលើសាកសពនោះដែរ។

ដូច្នេះតាមរយៈអំណះអំណាងខាងលើ ការតម្កល់តរឿងតតទុកចាត់ការ ដោយសារតែមានមរណភាពនៃជនល្មើស គឺជារឿងសមស្រប។ ព្រះរាជអាជ្ញាត្រូវណែនាំឲ្យជនរងគ្រោះប្ដឹងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងការខូចខាត និងសំណងនៃជម្ងឺចិត្តវិញ។

**ខ. ការផុតអាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្ដឹង**

ការផុតអាជ្ញាយុកាលនៃបទល្មើសក្នុងរឿងក្ដីព្រហ្មទណ្ឌមាន២ គឺអាជ្ញាយុកាលនៃបទល្មើស[50] និងអាជ្ញាយុកាលនៃទោស[51]។ ការផុតអាជ្ញាយុកាលត្រង់ចំណុចនេះ គឺសំដៅលើអាជ្ញាយុកាលនៃបទល្មើស ដែលជារយៈពេលនៃច្បាប់ក្នុងការធ្វើបណ្ដឹងអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ជនល្មើសក្នុងច្បាប់ព្រហ្មទណ្ឌ។ អាជ្ញាយុកាលនៃបទល្មើសមានភាពខុសគ្នាទៅតាមប្រភេទនៃបទល្មើសដែលបានចែងតាមស្ថានទម្ងន់នៃទោសដែលមានដូចជា៖

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា៨ កថាខណ្ឌទី១ ។

[49] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា៤២ ។

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា១០ កថាខណ្ឌទី១ ។

[51] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា១៨៤ ។

លើកលែងតែមានចែងក្នុងច្បាប់ពិសេស ដែលអាជ្ញាយុកាលខាងលើមិនត្រូវយកមកអនុវត្តឡើយ។ ក្នុងនោះមានដូចជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងបទល្មើសប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម[52]។ សរុបមកវិញ ប្រសិនបើបទល្មើសនីមួយៗត្រូវបានផុតកំណត់ នោះព្រះរាជអាជ្ញាមិនបានធ្វើបណ្ដឹងអាជ្ញាដើម្បីប្ដឹងនរណាម្នាក់បានឡើយ ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**គ. ការលើកលែងទោសជាទូទៅ**

ច្បាប់ស្ដីពីការលើកលែងទោស ដែលត្រូវបានអនុម័តដោយរដ្ឋសភា[53]។ ការលើកលែងទោសជាទូទៅនេះមានអនុភាពលុបចោលនូវទណ្ឌកម្មទាំងឡាយ ដែលពាក់ព័ន្ធជាមួយនឹងច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ហើយទោសមិនអាចអនុវត្តបានទៀតនោះឡើយ ចំណែកឯទោសដែលកំពុងអនុវត្តគឺត្រូវតែបញ្ឈប់ ប៉ុន្តែចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្ដី ដែលបង់រួចហើយមិនអាចទាមទារសំណងពីរដ្ឋបានវិញទេ[54]។ តាមរយៈអត្ថន័យខាងលើបានសេចក្ដីថា ការលើកលែងទោសជាទូទៅមានគោលបំណង ដកចេញនូវរាល់ទណ្ឌកម្មទាំងឡាយដែលត្រូវអនុវត្ត ឬកំពុងបាននឹងអនុវត្តចំពោះជនល្មើស។

**ឃ. និរាករណ៍នៃច្បាប់**

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺជាការច្រានចោលនូវបញ្ញត្តច្បាប់ចាស់ ដែលផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ថ្មី ដែលច្បាប់ថ្មីនោះបានចូលជាធរមាន។ ចំណុចនេះ គឺទាក់ទងជាមួយនឹងគោលការនីត្យានុកូល ព្រោះច្បាប់ដែលគេអាចយកមកអនុវត្តលើបទល្មើសបាន លុះត្រាតែច្បាប់នោះបានចូលជាធរមាន និងមិនត្រូវបាននិរាករណ៍។ ក្នុងករណីដែលបទប្បញ្ញត្តិច្បាប់នោះនិរាករណ៍ ហើយមានបទល្មើសពាក់ព័ន្ធ ក៏ពុំអាចយកច្បាប់នោះមកអនុវត្តលើបទល្មើសនោះបានដែរ។

ដូច្នេះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះបទល្មើសទាក់ទងនឹងបញ្ញត្តនិរាករណ៍ ហើយពុំមានបទប្បញ្ញត្តិថ្មីណាដើម្បីធ្វើការចោទប្រកាន់ទៀតឡើយ។ ចំពោះទោសដែលបានប្រកាសរួចហើយ ក៏ត្រូវបានបញ្ឈប់ផងដែរ[55]។

**ង. អាជ្ញាអស់ជំនុំ**

អាជ្ញាអស់ជំនុំសំដៅលើរឿងហេតុដែលតុលាការបានសម្រេចឲ្យជនណារួចខ្លួនជាស្ថាពរ ជននោះមិនអាចចោទប្រកាន់សារជាថ្មីលើរឿងក្ដីដដែលបានឡើយ ទោះក្រោមការកំណត់ឈ្មោះបទល្មើសសារជាថ្មីក៏

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា៩ ។

[53] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា៩០ ថ្មី (ពីរ) កថាខណ្ឌទី៤ ។

[54] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា១៤៩ ។

[55] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា៩ កថាខណ្ឌទី២ ។

ដោយ[56]។ មានន័យថា ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះជនដដែលនោះធ្លាប់ត្រូវបានតុលាការប្រកាសឲ្យរួចផុតពីបទចោទប្រកាន់ដំបូងចំពោះបទល្មើសដដែល ដែលគេប្ដឹងសុំមកព្រះរាជអាជ្ញា ឲ្យបើកការចោទប្រកាន់សារជាថ្មី។ ក្នុងករណីខ្លះ ដែលព្រះរាជអាជ្ញាបានសម្រេចតម្កល់រឿងទុកឥតចាត់ការ ពុំនាំឲ្យមានអាជ្ញាអស់ជំនុំឡើយ[57]។ បើព្រះរាជអាជ្ញាចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការអង្គហេតុមួយរួចក្រោយមករកឃើញថាអង្គហេតុនោះជាបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចយករឿងក្ដីនោះចោទប្រកាន់ជាថ្មីបាន។

**ច. ការសម្របសម្រួលជាមួយរដ្ឋ**

បណ្ដឹងអាជ្ញាអាចរលត់ ប្រសិនបើមានការសម្របសម្រួលជាមួយនឹងរដ្ឋ[58]។ ប៉ុន្តែ ការសម្របសម្រួលនេះអាចធ្វើបាន លុះត្រាណាតែមានចែងក្នុងច្បាប់ពិសេសដែលអនុញ្ញាតឲ្យមានការសម្របសម្រួល។ ការសម្របសម្រួលនេះទៀតសោត អាចកើតមានឡើងបានក្នុងករណីដែលអំពើនោះ ពុំបានបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈ ហើយជនដែលបានប្រព្រឹត្តបានទទួលស្គាល់កំហុស និងសន្យាកែប្រែកំហុស។

**ឆ. ការដកពាក្យបណ្ដឹង**

ការដកពាក្យបណ្ដឹងពីជនរងគ្រោះ អាចធ្វើទៅបានចំពោះបទល្មើសមួយចំនួន ដែលច្បាប់ដោយឡែកបានកំណត់ជាក់លាក់ ហើយពាក្យបណ្ដឹងនោះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់។ ប្រសិនបើសហព័ទ្ធបានស្នើសុំកុំឲ្យចោទប្រកាន់[59] ដូច្នេះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ម្យ៉ាងទៀតបើមានការស្នើសុំពីជនរងគ្រោះមិនឲ្យចោទប្រកាន់ក្នុងបទល្មើសលហុ និងបទមជ្ឈិមស្រាល នោះព្រះរាជអាជ្ញាក៏មិនអាចធ្វើការចោទប្រកាន់បានដែរ។ សំណើរនេះត្រូវបានចាត់ទុកថាជាការដកពាក្យបណ្ដឹង ដែលនាំឲ្យបណ្ដឹងអាជ្ញាត្រូវបានរលត់។

**២.២ មូលហេតុគតិយុត្តផ្សេងទៀត**

ក្រៅពីការផុតរលត់នៃបណ្ដឹងអាជ្ញា ដែលនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ក៏នៅមានមូលហេតុគតិយុត្តិផ្សេងទៀត ដែលមានបញ្ញាត្តក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលនាំឲ្យព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បាន។ មូលហេតុគតិយុត្តិទាំងនោះមានដូចជាៈ អភ័យឯកសិទ្ធិ អនិយ័តភាពនៃនីតិវិធី និងការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស។

**ក. ការមានអភ័យឯកសិទ្ធ**

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា១២ ។

[57] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា៩ កថាខណ្ឌទី១ ។

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា៨ កថាខណ្ឌទី១ ។

[59] ច្បាប់ស្ដីពីឯកពន្ធភាព មាត្រា៨ ។

អភ័យឯកសិទ្ធ គឺជាសិទ្ធិពិសេសរបស់បុគ្គលណាមួយដែលមានច្បាប់បញ្ញត្តឲ្យ អំពីលក្ខខណ្ឌពិសេសទាក់ទងនឹងនីតិវិធី ការទទួលខុសត្រូវ ឬការទទួលបាននូវស្ថានសម្រាលចំពោះការប្រព្រឹត្តបទល្មើសណាមួយ។ តាមរយៈបញ្ញត្តពិសេសនេះដែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង បានផ្តល់ឲ្យតែចំពោះបុគ្គលមួយចំនួនតែប៉ុណ្ណោះ។ ជាក់ស្តែង មាត្រា៨០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិ តំណាងរាស្ត្រណាក៏ដោយក៏មិនត្រូវបានចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬឃុំខ្លួនបានឡើយ លុះត្រាមានការយល់ព្រមពីរដ្ឋសភានៅក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា។ នៅមានបុគ្គលមួយចំនួនទៀតដូចជា ព្រះមហាក្សត្រ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា តំណាងទូត និងមានអភ័យឯកសិទ្ធិគ្រួសារចំពោះបទល្មើសលួច។ គួរបញ្ជាក់ផងដែរថា ការមិនចោទប្រកាន់ចំពោះបុគ្គលដែលមានអភ័យឯកសិទ្ធិនេះ មិនមែនជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ គឺគ្រាន់តែជាមូលហេតុគតិយុត្តផ្សេងទៀត ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការតែប៉ុណ្ណោះ។

**ខ. គ្មានពាក្យបណ្តឹងពីជនដែលច្បាប់បានកំណត់**

អំពើដែលច្បាប់បានកំណត់ថា ជាបទល្មើសដរាបណាច្បាប់បានកំណត់ដោយជាក់លាក់ ថាវាពិតជាបានធ្វើឲ្យសង្គមល្អក់កករ ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់របស់សង្គម។ ដោយឡែកអំពើមួយចំនួនបានប៉ះពាល់លើកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល ដូចជាបទបរិហាកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩) និងអំពើបរិហាតាមសារព័ត៌មាន (មាត្រា៣០៦) បទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧) និងអំពើជេរប្រមាថតាមសារព័ត៌មាន (មាត្រា៣០៨) អាចធ្វើការចោទប្រកាន់ទៅបាន លុះត្រាតែមានបណ្តឹងពីជនដែលច្បាប់បានកំណត់។ បានសេចក្តីថា ករណីទាំងនោះត្រូវធ្វើឡើងតាមបណ្តឹងនៃសាមីបុគ្គល។ ក្នុងករណីមានបទបរិហា ឬការជេរប្រមាថលើមន្ត្រីរាជការ សមាជិករាជរដ្ឋាភិបាល ឬពលរដ្ឋទទួលបន្ទុកបេសកកម្មសាធារណៈ បណ្តឹងត្រូវឡើងពីប្រធានស្ថាប័ន។

**គ. អនិយ័តភាពក្នុងនីតិវិធី**

អនិយ័តភាព សំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធីក្នុងដំណើរប្រតិបត្តិការ របស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ឬក្នុងការស្រាវជ្រាវបន្ថែម របស់នគរបាលយុត្តិធម៌ ដែលវាហាក់មានភាពមិនស្របនឹងនីតិវិធីនៃច្បាប់ និងមិនបានលទ្ធផល ឬគ្មានប្រយោជន៍។ ព្រះរាជអាជ្ញាអាចសំអាងលើមូលហេតុនេះដើម្បីចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។

**ឃ. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស**

ការមិនទទួលខុសត្រូវរបស់ជនល្មើស សំដៅទៅដល់ការមិនទទួលទោសផ្នែកព្រហ្មទណ្ឌរបស់ជនល្មើស ដែលមានច្បាប់ចែងយ៉ាងជាក់លាក់។ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា បានចែង

អំពីមូលហេតុនៃការរួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដែលមានដូចជា៖

- **វិបល្លាសស្មារតី**[60]៖ កាលណាបើជនណាម្នាក់បានប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតមាននូវវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌឡើយ។ ប៉ុន្តែបើការកាត់បន្ថយការយល់ដឹងខុសត្រូវ នៅពេលដែលជននោះបានសេពនូវគ្រឿងស្រវឹង សេពគ្រឿងញៀន ជននោះពុំអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។

- **ការអនុញ្ញាតដោយច្បាប់ ឬដោយអាជ្ញាធរ**[61]៖ សំដៅទៅលើអាជ្ញាធរសាធារណៈមានដូចជានគរបាលកងរាជអាវុធហត្ថជាដើម ដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតដោយច្បាប់ ឬតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់បុគ្គលទាំងនោះមិនប្រព្រឹត្តបទល្មើសនោះទេលើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ទោះក្នុងមូលហេតុណាក៏ដោយ។

- **ការការពារស្របច្បាប់**[62]៖ ច្បាប់បានអនុញ្ញាតឲ្យបុគ្គលណាដែលប្រព្រឹត្តបទល្មើស ក្នុងសភាពការការពារស្របច្បាប់ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែការការពារស្របច្បាប់នោះត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖ បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ដែលប្រឈមមុខនឹងការឈ្លានពានមួយមិនត្រឹមត្រូវ បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

- **សច្ចធារណ៍នៃការការពារស្របច្បាប់**[63]៖ ការសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណី ដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយសារកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សរស់នៅ។ បទល្មើស បានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្រព្រឹត្តដោយហិង្សា។ សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះអាចត្រូវរលាយដោយសារការរកបាននូវភស្តុតាងផ្ទុយ។

- **ស្ថានភាពចាំបាច់**[64]៖ ស្ថានភាពចាំបាច់ សំដៅទៅលើបុគ្គលដែលស្ថិតនៅក្នុងការចាំចាច់ត្រូវតែប្រព្រឹត្ត

[60] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣១ ។
[61] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣២ ។
[62] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៣ ។
[63] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៤ ។
[64] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៥ ។

បទល្មើស មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចជា បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬនឹងកើតមាន និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ ។

- **អនុភាពនៃកម្លាំង ឬការបង្ខំ[65]៖** សំដៅទៅដល់បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអនុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនេះមិនអាចទប់ទល់បាននោះ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។
- **ជនល្មើសជាអនីតិជនអាយុក្រោម ១៤ ឆ្នាំ៖** អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនត្រូវទទួលទោសព្រហ្មទណ្ឌទេ[66] ប៉ុន្តែអំពើដែលអនីតិជនបានប្រព្រឹត្ត ឪពុក-ម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជនជាអ្នក ទទួលខុសត្រូវទៅលើសំណងរដ្ឋប្បវេណី ។

សរុបជារួមមក បើទោះបីជាអំពើខាងលើជាបទល្មើសព្រហ្មទណ្ឌក៏ពិតមែន ក៏ជនល្មើសខាងលើមិនបានចោទប្រកាន់ដែរ ព្រោះអំពើទាំងនោះច្បាប់បានកំណត់ច្បាស់ថាជាអំពើយុត្តិកម្ម។ ដូច្នេះព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ជនល្មើសខាងលើបានឡើយ ហើយត្រូវចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

### ៣. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

កម្មវត្ថុនៃការចោទប្រកាន់ គឺជាការទាមទារឲ្យជនល្មើសមកទទួលខុសត្រូវព្រហ្មទណ្ឌ ហើយចាំបាច់ក្នុងការធានាដល់សិទ្ធរបស់ជនរងគ្រោះ ដើម្បីទទួលបាននូវសំណងព្យសនកម្មដែលខ្លួនបានទទួល។ ប៉ុន្តែចំពោះការចោទប្រកាន់មួយចំនួន ដែលអាចធ្វើឲ្យព្រះរាជអាជ្ញាពិចារណាយល់ថា ជាការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ ឬឥតបានការ នាំឲ្យខាតពេលវេលា មិនមានប្រយោជន៍ដល់ជនរងគ្រោះ និងដើមបណ្តឹង ឬផលប្រយោជន៍សាធារណៈ ហើយមិនមានលទ្ធភាពក្នុងការសម្រេចនូវកម្មវត្ថុនៃការចោទប្រកាន់ ព្រះរាជអាជ្ញាអាចសម្រេចតម្កលល់រឿងឥតទុកចាត់ការ។

មូលហេតុដែលបណ្តាល ឲ្យការចោទប្រកាន់ មិនផ្តល់ផលប្រយោជន៍ អាចបណ្តាលមកពីមូលហេតុផ្សេងៗដូចជា[67]៖

- ការស្វែងរកមិនបានផល
- ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង

---

[65] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៦ ។

[66] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៩ កថាខណ្ឌទី២ ។

[67] និទ្ទេសនៃដីការតម្កល់រឿងទុកកឥតចាត់ការ ។

- ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនៃការយល់ដឹងរបស់ជនល្មើស
- ការខកខានរបស់ដើមបណ្តឹង
- អាកប្បកិរិយារបស់ជនរងគ្រោះ
- ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស
- ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើសជាអាទិ៍។

**៤. ជម្រើសនៃការណែនាំ**

មានរឿងក្តីមួយចំនួនដែលព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់ បញ្ជូនរឿងឲ្យស៊ើបសួរ ឬបញ្ជូនរឿងទៅជំនុំជម្រះឡើយ ព្រោះក្នុងករណីទាំងនោះអាចបណ្តាលមកពីស្ថានភាពសង្គម ស្ថានភាពនៃអាយុ ឬទាក់ទងនឹងការយល់ដឹងរបស់ជនល្មើស។ ដូចក្នុងករណីអនីតិជនសេពគ្រឿងញៀន ដោយសារតែការអូសទាញនៃសង្គម តាមមិត្តភក្តិ ឬការចង់សាកដឹង ដូច្នេះគប្បីឲ្យព្រះរាជអាជ្ញាស្រាវជ្រាវឲ្យបានច្បាស់ ដើម្បីមិនធ្វើការចោទប្រកាន់ទៅលើអនីតិជនរូបនោះ ហើយមកជាការអប់រំ និងបញ្ជូនអនីតិជនទៅកាន់មណ្ឌលកែប្រែ មណ្ឌលព្យាបាលគ្រឿងញៀន មណ្ឌលបន្សាបគ្រឿងញៀន ឬមណ្ឌលស្តានីតិសម្បទារ ។

**ផ្នែកទី២ ៖ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។ ទម្រង់នៃការតម្កល់រឿងទុកឥតចាត់ការមានធាតុ២សំខាន់គឺ សំអាងហេតុ និងសំអាងច្បាប់[68]។ មានធាតុ២នេះ ទើបដីកាមានភាពត្រឹមត្រូវ និងច្បាស់លាស់។ សំអាងហេតុ សំដៅលើការលើកយកនូវអង្គហេតុទាំងឡាយដែលពាក់ព័ន្ធមកធ្វើជាសំអាង ព្រមទាំងមានការវិនិច្ឆ័យគ្រប់ជ្រុងជ្រោយរបស់ព្រះរាជអាជ្ញា ដែលនាំឲ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។ រីឯសំអាងច្បាប់ គឺជាការលើកយកនូវបញ្ញត្តច្បាប់មកធ្វើជាទឡ្ហីករណ៍ ដើម្បីសម្រេចមិនធ្វើការចោទប្រកាន់។

ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងតាមនីតិវិធីមួយយ៉ាងច្បាស់លាស់ ត្រឹមត្រូវតាមទម្រង់នៃដីកា ដើម្បីឲ្យដីកាសម្រេចនោះមានអានុភាពក្នុងការអនុវត្ត។

**១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ**

បន្ទាប់ពី ព្រះរាជអាជ្ញាសម្រេចមិនធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវធ្វើចេញនូវសេចក្តីសម្រេចមួយតាមរយៈដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ព្រះរាជអាជ្ញា ត្រូវជូនដំណឹងទៅដល់អ្នកប្តឹងវិញយ៉ាងយូរបំផុត រយៈពេល២ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងនៅក្នុងបញ្ជី[69] ដោយធ្វើឡើងតាមរយៈលិខិតជូនដំណឹង។

---

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១ កថាខណ្ឌទី២ ។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១ កថាខណ្ឌទី១ ។

ការជូនដំណឹងនេះ ធ្វើឡើងក្នុងគោលបំណងគោរពដល់ដើមបណ្តឹង ដើម្បីឲ្យគេបានទទួលពីសេចក្តីសម្រេចរបស់ ព្រះរាជអាជ្ញា ដែលបានសម្រេចលើបណ្តឹងរបស់ខ្លួន ហើយដើម្បីធានានូវសិទ្ធិដើមបណ្តឹងក្នុងការតវ៉ាទៅនឹងសេចក្តីមសម្រេចនេះផងដែរ។ រយៈពេលនៃការឲ្យដំណឹងគឺយ៉ាងយូរបំផុត គឺ២ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងក្នុងបញ្ជី ដែលបញ្ជីនោះជាបញ្ជីអយ្យការសម្រាប់ចុះបណ្តឹងនៅតាមតុលាការជាន់ដំបូងនីមួយៗ ហើយស្ថិតនៅក្រោមការកាន់កាប់របស់លេខាធិការបស់អយ្យការ និងក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាផ្ទាល់[70]។ ការឲ្យដំណឹងដល់ដើមបណ្តឹងកាន់តែឆាប់គឺកាន់តែល្អ ដើម្បីឲ្យគេមានពេលវេលាគ្រប់គ្រាន់ សម្រាប់ការពិចារណាទៅលើសេចក្តីសម្រេចនេះ ថាតើគួរទទួល ឬក៏ធ្វើការប្តឹងតវ៉ា។

### ២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គ្មានអាជ្ញាអស់ជំនុំទេ[71]។ មានន័យថា ប្រសិនបើព្រះរាជអាជ្ញាសម្រេចមិនធ្វើការប្រកាន់ មិនមែនបានសេចក្តីថាជននោះរួចផុតពីការចោទប្រកាន់ជាស្ថាពរនោះទេ ក្នុងករណីដែលព្រះរាជអាជ្ញាស្វែងរក ឬទទួលបាននូវភស្តុតាងថ្មីសម្រាប់ធ្វើការដាក់បន្ទុក ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់សារជាថ្មីបានម្តងទៀត លើកលែងតែផុតរលត់បណ្តឹងអាជ្ញា។ ការកំណត់អាជ្ញាអស់ជំនុំមិនអាចស្តែងបានឡើយ ព្រោះវាជាការផ្តោតតែលើការសម្រេចដោយឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា ដែលបានធានាដល់សិទ្ធិរបស់ជនរងគ្រោះនៃអំពើល្មើស ដើម្បីឲ្យមានការសើរើឡើងវិញចំពោះការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាធ្វើការសម្រេចដោយមានការខុសឆ្គង ឬមានចន្លោះប្រហោងត្រង់ចំណុចណាមួយ។

## ផ្នែកទី៣ ៖ យន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ

ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីមួយមានលក្ខណៈមិនដាច់ខាត ដែលព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់ចំពោះជនណាមួយក្នុងរឿងក្តីព្រហ្មទណ្ឌ។ ទោះបីជា រឿងក្តីត្រូវបានតម្កល់ទុកឥតចាត់ការក៏ពិតមែន ក៏នៅមានយន្តការជម្រុញឲ្យមានការលើកយកមកដោះស្រាយដែរ។ យន្តការទាំងនោះត្រូវធ្វើឡើងតាមរយៈ ការសើរើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាប្តឹងតវ៉ាទៅ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គអយ្យការ និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

ដូច្នេះហើយ ការបើកផ្លូវឲ្យព្រះរាជអាជ្ញាធ្វើការសើរើកែប្រែសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ គឺជានីតិវិធីជួយឲ្យព្រះរាជអាជ្ញាក្នុងគោលបំណងបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយដើម្បីការពារនូវផលប្រយោជន៍របស់ជនរងគ្រោះនៃអំពើល្មើសឲ្យទទួលបានយុត្តិធម៌ផងដែរ។

---

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៥០។

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១ កថាខណ្ឌទី២ ។

## ១. បណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

បណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជានីតិវិធីមួយដែលបានផ្ដល់នូវអាទិភាពដល់ដើមបណ្ដឹង ដើម្បីអាចប្ដឹងតវ៉ាពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញាដែលខ្លួនបានទទួល ឬពាក្យបណ្ដឹងស្ថិតនៅដោយគ្មានចម្លើយ[72]។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានកំណត់តួនាទីលើការឃ្លាំមើលអំពីការអនុវត្តច្បាប់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[73] ដោយសារតួនាទីនេះ ទើបច្បាប់សម្រេចយកអគ្គព្រះរាជអាជ្ញាជាអ្នកទទួលពាក្យបណ្ដឹងពីជនរងគ្រោះ ដែលប្ដឹងតវ៉ាលើសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ការធ្វើបណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានរយៈពេល២ខែ គិតចាប់ពីពេលដែលខ្លួនបានទទួលសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា។ ចំពោះបញ្ញត្តច្បាប់មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា បណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងនៅពេលដែលបណ្ដឹងរបស់ខ្លួនត្រូវបានសម្រេចតម្កល់រឿងទុកឥតចាត់ការ។ សំរាប់ជនរងគ្រោះ ដែលមិនបានទទួលនូវសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញាវិញ គឺថេរវេលាខាងលើមិនអាចប្រើប្រាស់ ក្នុងករណីបណ្ដឹងស្ថិតនៅដោយគ្មានចម្លើយបានឡើយ ដោយសារតែមិនមានការកម្រិតរយៈពេលចំពោះជនរងគ្រោះ ដែលនាំឲ្យជននោះអាចប្ដឹងពេលណាក៏បានឲ្យតែខ្លួនយល់ថាបណ្ដឹងរបស់ខ្លួនស្ថិតនៅគ្មានចម្លើយ។

នីតិវិធីនៃការធ្វើបណ្ដឹងតវ៉ា ត្រូវធ្វើឡើងដោយបណ្ដឹងសាមញ្ញរបស់អ្នកប្ដឹងទៅអង្គការអយ្យការ ដែលមានការពាក់ព័ន្ធ។ អង្គការអយ្យការដែលពាក់ព័ន្ធ សម្ដៅដល់អង្គការអយ្យការអមសាលាដំបូងដែលទទួលបានបណ្ដឹងលើកទី១។ នៅពេលបណ្ដឹងត្រូវបានដាក់រួច ព្រះរាជអាជ្ញាអមសាលាដំបូងត្រូវបញ្ជូនសំណុំរឿងមកឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីធ្វើការសម្រេច។ ការសម្រេចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចមាន២ករណី៖ ការបដិសេធនិងសេចក្ដីសម្រេច និងការយល់ស្របនឹងសេចក្ដីសម្រេច។

- **ការបដិសេធនិងសេចក្ដីសម្រេច៖** បើពិនិត្យទៅឃើញថាបណ្ដឹងនោះមានភាពត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងចេញអធិបញ្ញា ដើម្បីឲ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់ឡើងវិញ។ អធិបញ្ញា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ដាច់ខាត មិនអាចសម្រេចមិនធ្វើការចោទប្រកាន់ដូចមុនបានឡើយ។
- **ការយល់ស្របនិងសេចក្ដីសម្រេច៖** ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មិនយល់ស្របនិងបណ្ដឹងតវ៉ានេះទេ ដូច្នេះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងសម្រេចតម្កល់សេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាការបាន ហើយជូនដំណឹងទៅកាន់អ្នកប្ដឹងវិញ ដោយអ្នកប្ដឹងនេះមិនអនុញ្ញាតឲ្យធ្វើការ

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៦ កថាខណ្ឌទី២ ។
[73] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៣ កថាខណ្ឌទី១ ។

ប្តឹងតវ៉ាម្តងទៀតទេ។ ការជូនដំណឹងនេះ ដើម្បីជាឱកាសក្នុងការប្រើនីតិវិធីផ្សេងៗទៀត ដូចជាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរជាដើម[74]។

**២. អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ**

ជាទូទៅ រចនាសម្ព័ន្ធរបស់អង្គការអយ្យការមានបីថ្នាក់ ខាងក្រោមនេះជាឋានានុក្រមតាមថ្នាក់តុលាការដែលខ្លួននៅអមជាមួយ ឬឋានានុក្រមរដ្ឋបាលតុលាការដែលចៅក្រមអយ្យការមាន៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។

សូមបញ្ជាក់ថា ឋានានុក្រមនៃអង្គការអយ្យការនេះមិនសំដៅដល់ប្រភេទឋានានុក្រម ដែលកំណត់ដោយមាត្រា២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នោះទេ។ អំណាចអធិបញ្ញាតាមន័យទូទៅ គឺជាការបញ្ជាតាមឋានានុក្រមពីថ្នាក់លើមកក្រោមដើម្បីបញ្ជាឲ្យធ្វើអ្វីមួយ។ យោងតាម មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ សំដៅដល់ការបញ្ជាតាមឋានានុក្រមឲ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌណាមួយ។ ការបង្កើតអំណាចអធិបញ្ញានេះ មិនចាំបាច់មានបណ្តឹងពីជនណាមួយ ទើបមានចំណាត់ការនោះទេ តែជាតួនាទីត្រួតពិនិត្យក្នុងនាមជាអាជ្ញាធរ ដែលច្បាប់បានកំណត់ប្រគល់សិទ្ធិផ្តាច់មុខចូលរួមអនុវត្តន៍ច្បាប់ និងទប់ស្កាត់ការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិព្រះរាជអាជ្ញា ដែលគ្មានហេតុផលសមស្របទៅនឹងស្ថានភាពសង្គម។ សមាសភាពនៃអង្គការអយ្យការក្នុងការធ្វើអធិបញ្ញាមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។

**២.១. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមុខនាទីមួយដែលតំណាង ឬជាសេនាធិការរាជរដ្ឋាភិបាលក្នុងការពង្រឹងវិស័យច្បាប់។ ច្បាប់បានផ្តល់សិទ្ធិអំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅព្រះរាជអាជ្ញាអមសាលាដំបូង ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឲ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសម្រេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលខ្លួនយល់ឃើញថាការគួរ។

**២.២. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអ្នកឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដី នៃសាលា

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៥ ។

ឧទ្ធរណ៍[75]។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចនៃដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឲ្យចោទប្រកាន់ ឬធ្វើសេចក្តីសម្រេចឲ្យសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញ។ បានសេចក្តីថា អគ្គព្រះរាជអាជ្ញាមានអំណាចក្នុងការធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការ។

### ២.៣. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញានៅពេលនេះមិនមែនសំដៅលើព្រះរាជអាជ្ញាអមសាលាកំពូល ឬក៏ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទេ ព្រោះអ្នកទាំងនេះមិនមានអំណាចលើចៅក្រមអយ្យការណាមួយ ក្នុងការប្រើអំណាចអធិបញ្ញា។ ព្រះរាជអាជ្ញាពេលនេះ គឺសម្តៅលើព្រះរាជអាជ្ញាអមសាលាដំបូង។ ព្រះរាជអាជ្ញាមានអំណាចលើចៅក្រមអយ្យការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឲ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់ឲ្យធ្វើការចោទប្រកាន់ ឬធ្វើសេចកក្តីសន្និដ្ឋានតាមដែលខ្លួនយល់ឃើញជាការគួរ។ ដូចនេះមានន័យថា ព្រះរាជអាជ្ញាអមសាលាដំបូង អាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារង ដែលស្ថិតនៅក្នុងដែនដី ឬនៅអមសាលាដំបូង ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកកឥតចាត់ការបានធ្វើឡើង។

## ៣. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

ក្រៅពីជម្រើសនៃការដាក់ពាក្យបណ្តឹងទាមទារ ឬពាក្យប្តឹងបរិហាទៅមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាផ្ទាល់ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពប្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរ[76]។ ពាក្យប្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា[77] ដែលអាចនាំឲ្យមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ។ បន្ទាប់មកចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យបណ្តឹង ដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរបញ្ជូនដំណឹងនេះទៅព្រះរាជអាជ្ញា។ ក្រោយពីបានទទួលពាក្យបណ្តឹង ដែលមានការតាំងខ្លួនជាដើម្បីរដ្ឋប្បវេណីព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅកក្រមស៊ើបសួរ តាមដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ទោះបីជាមានការស្នើ

---

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៥ ។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៣៨ ។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤ ។

សុំមិនឲ្យបើកការស៊ើបសួរពីព្រះរាជអាជ្ញាក៏ដោយ ក៏ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចចំពោះការស្នើនេះដែរ។ ហើយចៅក្រមស៊ើបសួរនៅតែអាចសម្រេចលើពាក្យបណ្តឹងនោះ ដោយឯករាជ្យដដែលដោយៈ

- **ការសម្រេចមិនបើកការស៊ើបសួរៈ** ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងនេះជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។
- **សម្រេចបើកការស៊ើបសួរៈ** ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមានសំអាងហេតុ ហើយជូនដំណឹងដល់ព្រះរាជអាជ្ញា។

ដីកាសម្រេចខាងលើរបស់ចៅក្រមស៊ើបសួរ សុទ្ធតែអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន ដោយដើមបណ្តឹងរដ្ឋប្បវេណី[78] និងព្រះរាជអាជ្ញា[79]។

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៦៨

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៦៦

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការបកស្រាយយ៉ាងក្បោះក្បាយខាងលើរួចមក យើងអាចសន្និដ្ឋានបានថា ស្ថាប័នអយ្យការ ជាពិសេសគឺអយ្យការអមសាលាដំបូង ពិតជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងនីតិវិធីនៃការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌ។ អយ្យការ ធ្វើការក្នុងនាមជាអ្នកបម្រើផលប្រយោជន៍សាធារណៈសុទ្ធសាធ ហើយភារកិច្ចចំបងរបស់អយ្យការ គឺការធ្វើចំណាត់ការចំពោះបទល្មើស។ ព្រះរាជអាជ្ញាមានសិទ្ធធ្វើការចោទប្រកាន់ និងមិនចោទប្រកាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានផ្តល់វិធី៣យ៉ាងសម្រាប់ឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅលើបទល្មើសគឺ ការបើកការស៊ើបសួរ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម។ បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងលំអិតទៅលើនីតិវិធីនៃការចោទប្រកាន់នីមួយៗ យើងបានរកឃើញ និងកំណត់បាននូវមូលហេតុដែលនាំឲ្យមានការបង្កើតឡើងនូវនីតិវិធីនៃការចោទប្រកាន់ផ្សេងៗគ្នា គឺដើម្បីធានានូវភាពច្បាស់លាស់ និងភាពឆាប់រហ័សនៃរឿងក្តីព្រហ្មទណ្ឌ។ ភាពច្បាស់លាស់ ត្រូវបានកំណត់គ្រប់ដំណាក់កាលនៃនីតិវិធីនៃការចោទប្រកាន់ទាំងអស់ ដើម្បីស្វែងរកយុត្តិធម៌យ៉ាងពិតប្រាកដ ជូនដល់ជនរងគ្រោះ និងជនជាប់ចោទ ព្រមទាំងការពារនូវផលប្រយោជន៍សាធារណៈ និងបញ្ឈប់រាល់ភាពចលាចលនានានៅក្នុងសង្គម។ ប្រសិនបើការចោទប្រកាន់នៅក្នុងរឿងក្តីមិនមានភាពច្បាស់លាស់នោះទេ ច្បាស់ណាស់ថានឹងកើតមានផលវិបាកជាច្រើនមិនចំពោះតែទៅលើដើមបណ្តឹង ឬចុងចម្លើយនោះទេ សូម្បីតែរដ្ឋក៏បង់ផលប្រយោជន៍ផងដែរ។ ចំពោះចុងចម្លើយ គឺអាចនឹងខាតបង់ពេលវេលា ប្រសិនបើមានការចាប់ឃុំ ព្រមទាំងខាតបង់ប្រាក់កាស ជាពិសេសគឺកិត្តិយស កេរ្តិ៍ឈ្មោះ ឬអាចទទួលរងនូវភាពអយុត្តិធម៌ ដែលបណ្តាលមកពីការពុំបានស៊ើបអង្កេតឲ្យបានច្បាស់លាស់ពីសំណាក់តំណាងអយ្យការ។ ចំណែកឯ ដើមបណ្តឹងវិញក៏មានផលប៉ះពាល់ផងដែរ ដូចជាការខាតប្រាក់កាស ពេលវេលា ក៏ដូចជាការមិនបានភាពយុត្តិធម៌ ឬសំណងប៉ះប៉ូវផ្លូវចិត្តជាយថាហេតុ ព្រោះតាមរយៈគោលការណ៍វិមតិសង្ស័យ ដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលបណ្តាលឲ្យជនល្មើសអាចរួចផុតពីការចោទប្រកាន់បាន។ ដូច្នេះ ដើម្បីធានាពីភាពច្បាស់លាស់ ការពារសិទ្ធិ និងបញ្ចៀសផលប៉ះពាល់នៃរឿងក្តី ត្រូវធ្វើឡើងតាមរយៈ នីតិវិធីបើកការស៊ើបសួរ ដែលជាជម្រើសល្អបំផុត ព្រោះនីតិវិធីនេះនឹងបើកការស្រាវជ្រាវលំអិតបន្ថែមទៀតតាមរយៈចៅក្រមស៊ើបសួរ។

នីតិវិធីនីមួយៗត្រូវតែធ្វើឡើងដោយភាពច្បាស់លាស់យ៉ាងពិតប្រាកដ ប៉ុន្តែ ព្រះរាជអាជ្ញាពុំអាចធ្វើការអូសបន្លាយពេលវេលាបានឡើយ ពោលគឺ ការធ្វើបែបនេះគឺបណ្តាលឲ្យខូចប្រយោជន៍របស់ភាគីនៃរឿងក្តី។ ប្រសិនបើ ព្រះរាជអាជ្ញាមានភាពច្បាស់លាស់ពីពិរុទ្ធនៃជនសង្ស័យរួចហើយ ព្រះរាជអាជ្ញា មិនចាំបាច់បើកការ

ស៊ើបសួរទៀតឡើយ។ ដូច្នេះ ព្រះរាជអាជ្ញា អាចសម្រេចបញ្ជូនជនសង្ស័យនោះទៅជំនុំជម្រះតែម្តង តាមរយៈនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម។ នីតិវិធីទាំងពីរនេះ ជានីតិវិធីដែលជួយក្នុងការពន្លឿនឲ្យរឿងក្តីមានភាពឆាប់រហ័ស ព្រមទាំងជួយសន្សំពេលវេលាដល់ជនរងគ្រោះ ដែលជនរងគ្រោះអាចទទួលបានយុត្តិធម៌ឆាប់ ទទួលបានសំណងប៉ះប៉ូវផ្លូវចិត្ត ផ្លូវកាយ និងផ្លូវសម្ភារៈបានទាន់ពេលវេលា។ ចំណែកឯតុលាការក៏ទទួលបានផលប្រយោជន៍ច្រើនផងដែរ ដែលជួយកាត់បន្ថយនូវសំណុំរឿង និងបន្ថយបន្ទុករបស់ចៅក្រមស៊ើបសួរ ពីព្រោះបច្ចុប្បន្នទោះបីជាមានច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ ដែលបានបែងចែកជាតុលាការជំនាញពិតមែន ប៉ុន្តែជាក់ស្តែងនៅតាមសាលាដំបូងរាជធានី-ខេត្ត មិនទាន់មានតុលាការជំនាញនោះទេ ភាគច្រើនបន្ទុកនៃសំណុំរឿងស៊ើបសួរ សំណុំរឿងជំនុំជម្រះ និងប្រភេទសំណុំរឿងផ្សេងៗ សុទ្ធតែជាបន្ទុករបស់ចៅក្រមនៃសាលាដំបូងរាជធានី-ខេត្ត។

ក្រៅពីការចោទប្រកាន់នៃបទល្មើស ព្រះរាជអាជ្ញាក៏អាចសម្រេចមិនធ្វើការចោទប្រកាន់លើជនចុងបណ្តឹងបានដែរ ទោះបីជាទង្វើនោះកំណត់ថាជាបទល្មើសក៏ដោយ។ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាថ្លឹងថ្លែងរួចហើយ ដោយសាររឿងក្តីនោះជារឿងក្តីតូចតាច ឬសម្រេចធ្វើការចោទប្រកាន់ ហើយបង្កឲ្យមានភាពរឹករវដែលនាំឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ ចំណាយពេលវេលាឥតប្រយោជន៍ ឬខាតបង់ថវិកាជាតិក្នុងរឿងនោះ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើការចោទប្រកាន់ តាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការបាន។ ការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា គឺគិតដល់ផលប្រយោជន៍សង្គមជាធំ ក៏ដូចជាផលប្រយោជន៍របស់តុលាការផងដែរ។ ប៉ុន្តែ នៅមានមូលហេតុគត្តិយុត្តមួយចំនួន ដូចបានរៀបរាប់ក្នុងជំពូកទី៣ ផ្នែកទី១រួចមកហើយ ដែលមានដូចជា មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាលនៃបទល្មើស ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹង គ្មានពាក្យបណ្តឹងពីជនដែលច្បាប់បានកំណត់ អនិយ័តភាពក្នុងនីតិវិធី និងការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស ដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ចំពោះរឿងក្តីមួយចំនួន ដោយបានប្រព្រឹត្តដោយជនល្មើស ដែលវាមានផលប៉ះពាល់តិចតួច ព្រះរាជអាជ្ញាអាចធ្វើការផាកពិន័យ ស្តីបន្ទោស ឬណែនាំជនល្មើស ដើម្បីឲ្យជនល្មើសមានឱកាសកែខ្លួន និងធ្វើជាពលរដ្ឋល្អឡើងវិញបាន។ ការសម្រេចមិនធ្វើការចោទប្រកាន់នេះ គឺពិតជាជួយន្ថយបន្ទុកនៃស្ថាប័នតុលាការ ក៏ដូចជាជួយឲ្យតុលាការមានពេលវេលាច្រើន ក្នុងការដោះស្រាយក្តីសំខាន់ផ្សេងៗទៀតផងដែរ។ ប៉ុន្តែ ទន្ទឹមនឹងការផ្តល់ផលប្រយោជន៍ជាច្រើន ក៏បង្កនូវគុណវិបត្តិផងដែរ។ ដោយគុណវិបត្តិ ត្រូវបានផ្តល់តាមរយៈការបង្កើតវប្បធម៌និទណ្ឌភាព។ ព្រះរាជអាជ្ញាមានសិទ្ធិសម្រេចមិនធ្វើការចោទប្រកាន់ ជនបង្ករអាចរួចផុតពីការទទួលទោសដែលខ្លួនបានប្រព្រឹត្ត ជួនកាលអាចបណ្តាលឲ្យមានអំពើពុករលួយ និងបណ្តាឲ្យជនរងគ្រោះ និងស្ថាប័នអយ្យការ ខាតពេល

វេលា និងប្រាក់កាសក្នុងការសើរើរឿងក្តីឡើងវិញ។ ទោះបីជា រឿងក្តីត្រូវបានតម្កល់ទុកឥតចាត់ការក៏ពិតមែន ក៏តុលាការមានយន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ ដែលយន្តការទាំងនោះមានដូចជា ការធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គអយ្យការ និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

សរុបជារួមមក ស្ថាប័នអយ្យការ ជាស្ថាប័នដែលមិនអាចខ្វះបាន គឺចាំបាច់បំផុតក្នុងដំណើរការនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ បើគ្មានការចូលរួមក្នុងការចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញា ក៏ពុំមាននូវកិច្ចស៊ើបសួរ ឬកិច្ចជំនុំជម្រះកើតឡើងផងដែរ។ ជម្រើសនៃការចោទប្រកាន់របស់ស្ថាប័នអយ្យការ បានដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ឆន្ទានុសិទ្ធិដល់ ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ឬសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើសព្រហ្មទណ្ឌ។ ទោះបីជា នីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាធ្វើឡើងខុសគ្នាក៏ដោយ ក៏ការចោទប្រកាន់ទាំងអស់មានចំណុចជារួមមួយគឺ ធានាពីផលប្រយោជន៍នៃភាគី និងស្វែងរកនូវយុត្តិធម៌ពិតប្រាកដ។ ចំណែកនីតិវិធីនៃការមិនចោទប្រកាន់ បានផ្តល់ទាំងគុណសម្បត្តិ និងគុណវិបត្តិ ប្រសិនបើនីតិវិធីនេះពុំបានសិក្សាស្រាវជ្រាវ ឬពុំមានសមត្ថភាពពិតប្រាកដក្នុងការថ្លឹងថ្លែង ដែលជាហេតុនាំឲ្យប៉ះពាល់សិទ្ធិជនរងគ្រោះ។

## ២. ការផ្តល់អនុសាសន៍

ឆ្លងតាមការបកស្រាយលំអិតរួចមក យើងអាចធ្វើការវិនិច្ឆ័យបានថា ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលបានដើរតួនាទីយ៉ាងសំខាន់ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងនីតិវិធីនៃការចោទប្រកាន់ទាំអស់ពិតមែន។ នីតិវិធីទាំងនេះ អាចប្រព្រឹត្តទៅបានរលូនល្អ ត្រឹមត្រូវ មានតម្លាភាព និងប្រកបដោយភាពយុត្តិធម៌ លុះត្រាព្រះរាជអាជ្ញាបំពេញតួនាទីរបស់ខ្លួន ដោយផ្អែកលើចំណុចសំខាន់ៗដូចជា៖

- ព្រះរាជអាជ្ញា ត្រូវមានសុភវិនិច្ឆ័យឲ្យបានត្រឹមត្រូវចំពោះជម្រើសណាមួយ ដែលត្រូវធ្វើការចោទប្រកាន់ដើម្បីឲ្យភាគីទាំងសងខាង ទាំងជនរងគ្រោះ និងជនបង្កអាចទទួលបាននូវយុត្តិធម៌ពីការវិនិច្ឆ័យដែលត្រឹមត្រូវ និងច្បាស់លាស់ ហើយវាអាចនាំឲ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយ នៅពេលដែលព្រះរាជអាជ្ញាធ្វើការវិនិច្ឆ័យខុស ដែលជាហេតុបណ្តាលឲ្យខាតផលប្រយោជន៍ ពេលវេលា និងកិត្តិយសរបស់ភាគីទាំងពីរ។
- ការមិនចោទប្រកាន់ គឺជាការបើកសិទ្ធិយ៉ាងទូលាយដល់ព្រះរាជអាជ្ញា ដែលផ្តល់ឱកាសឲ្យជនរងគ្រោះបានរួចផុតពីទោសព្រហ្មទណ្ឌ។ ដូច្នេះព្រះរាជអាជ្ញាត្រូវទាមទារឲ្យមានវិជ្ជាជីវៈ ក្រមសីលធម៌ ព្រហ្មវិហារធម៌ មានឆន្ទៈជួយជាតិ គិតប្រយោជន៍រួមជាធំ មិនមានចិត្តលោភៈ ទោសៈ កំឡុងពេលសម្រេចមិនធ្វើការចោទប្រកាន់លើជនល្មើស។ ដើម្បីឲ្យសង្គមជាតិពោរពេញដោយសន្តិភាពពិតប្រាកដ ទន្ទឹមនឹងនោះប្រជាពលរដ្ឋគ្រប់រូបបានទទួលយុត្តិធម៌ស្មើៗគ្នា។
- ការបណ្តុះបណ្តាល បំពេញបន្ថែម ក្រមនីតិវិធីព្រហ្មទណ្ឌ ទៅដល់មន្ត្រីអនុវត្តច្បាប់ ទាំងឡាយ

ឲ្យមានចំណេះដឹងទូលំទូលាយក្នុងការអនុវត្តច្បាប់ឲ្យប្រកបទៅដោយសក្តិសិទ្ធិភាព និងត្រឹមត្រូវទៅតាមច្បាប់កំណត់ដែលមានចែងក្នុងក្រមនេះ ។ ជាពិសេស គឺផ្តល់នូវពុទ្ធិដល់មន្ត្រី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ឲ្យបានយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានកាន់តែប្រសើរ ដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់។

- ធ្វើការលើកទឹកចិត្តដល់មន្ត្រីជំនាញដែលមាន តួនាទី ភារកិច្ចបម្រើក្នុងប្រព័ន្ធយុត្តិធម៌ទាំងនោះ តាមរយៈការលើកសរសើរ ក៏ដូចជាតំឡើងប្រាក់បៀវត្សឲ្យបានសមរម្យ ឬផ្តល់សេវាថែទាំសុខភាពសង្គម និងសេវាសំខាន់ផ្សេងៗទៀត ដែលជាប្រយោជន៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ដើម្បីចៀសវាងកុំឲ្យមានសកម្មភាពមិនប្រក្រតីណាមួយកើតឡើង ដូចជាមានការផ្ទុះប្រតិកម្មពីមហាជន ក៏ដូចជារាស្ត្រប្រជា តាមបណ្តាញសង្គមនានាដូចជា Facebook, Tik Tok, instagram ដែលជាផលអវិជ្ជមានទៅដល់អង្គភាព ប៉ះពាល់ដល់ស្ថាប័ន ក៏ដូចជាសាមីជនផងដែរ មិនតែប៉ុណ្ណោះសិទ្ធិអំណាចនៃការចោទប្រកាន់ថ្មីត្បិតតែត្រូវបានប្រគល់ជូនដល់អំណាចរបស់ស្ថាប័នអយ្យការពិតមែនក៏ត្រូវបានថ្លឹងថ្លែង និងមានចំណាត់ការណាមួយសមស្របតាមសមធម៌នោះដែរ មិនត្រូវបានធ្វើការចោទប្រកាន់ស្រេចតែចិត្តរបស់ខ្លួននោះឡើយ ។

# ឯកសារយោង

# ឯកសារយោង

❖ **លិខិតបទដ្ឋានគតិយុត្ត**

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៤. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៥. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៦. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី១៦ កក្កដា ឆ្នាំ២០១៤

៧. ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

៨.គោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៨ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

❖ **ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ**

១. សាស្ត្រាចារ្យ ម៉ម ចាន់ណែត, នីតិព្រហ្មទណ្ឌ, ឆ្នាំ២០១៩

២. សាស្ត្រាចារ្យ មីន សំអុល, នីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០២២

៣. សាស្ត្រាចារ្យ មីន សំអុល, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ២០២២

៤. លោក គន យឿន, មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់, បោះពុម្ពលើកទី៤ ឆ្នាំ២០១៨

៥. សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០២២

៦. សាស្ត្រាចារ្យ កើយ វិញគៀម, នីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០១៥

៧. លោក សុង ប៊ុនឃៀង និងលោក អាត ច័ន្ទដារា, គោលការណ៍ទូទៅនៃនីតិក្រមទាំងបួន (មេរៀនសង្ខេប) ឆ្នាំ២០១៤

៨. លោក កុយ នាម និងលោក ឡុង បញ្ញាវុឌ្ឍ, អយ្យការ (ប្រវត្តិ និងកាប្រៀបធៀប), បោះពុម្ពលើកទី១ឆ្នាំ២០០៦

៩. លោកស្រី ឌី លីឡា និងលោក ខាន់ សុខា, នីតិវិធីព្រហ្មទណ្ឌ

១០. សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ២០២២

❖ **គេហទំព័រផ្សេងៗ**

១. បណ្ណាល័យអេឡិចត្រូនិចភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមបណ្តាញសង្គមនានា ។

https://www.elibrary-rule.com

២. កិច្ចពិភាក្សាស្តីពីអង្គការអយ្យការនិងការផ្ញើបណ្តឹងអាជ្ញា៖

https://www.youtube.com/watch?v=bSQPNdGg4FM

៣. អង្គការអយ្យការ៖

https://www.youtube.com/watch?v=YFrx66fA7dc

៤. ការចោទប្រកាន់ និងស្ថាប័នអយ្យការ៖

https://www.youtube.com/watch?v=ITDrwk0keq0

៥. ទំព័រស្វែងយល់ពីច្បាប់ ប្រធានបទស្តីពី នីតិវិធីនៃការចោទប្រកាន់

https://drive.google.com/file/d/0B242T0ZzfZmvZHhaUTh2a2tEblk/view?resourcekey=0

wHTwfHsv1Q6fpb5tKzb7Iw

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តកណ្តាល
ចូល លេខ..........
ថ្ងៃទី 09 ខែ 09 ឆ្នាំ ២០២០
ម៉ោង 08 40

## <u>ពាក្យបណ្តឹង</u>

ខ្ញុំបាទឈ្មោះ អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ អាយុ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦៩ ផ្លូវ១៥៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តម ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្តាល**

*<u>ជាទីគោរព ។</u>*

**<u>កម្មវត្ថុ:</u>** សំណើសុំប្តឹងពីឈ្មោះ ភេទប្រុស អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិស្វាយជ្រំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល។

**<u>ពីបទ:</u>** ***ហិង្សាដោយចេតនា*** មកលើរូបខ្ញុំបាទនិងប្រពន្ធខ្ញុំបាទកាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ ត្រង់ចំណុចភូមិស្វាយជ្រំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ។

**<u>យោង:</u>** -រូបថតដែលថតកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ចំនួន០៣(បី)សន្លឹក បានបញ្ជាក់អំពីសកម្មភាពដែលឈ្មោះ បានប្រើហិង្សាមកលើខ្ញុំបាទ ។

-ខ្សែអាត់វីឌីអូចំនួន៤៥វិនាទីដែលថតកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បានបញ្ជាក់អំពីសកម្មភាពដែលឈ្មោះ បានប្រើហិង្សាមកលើខ្ញុំបាទ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ មានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តម ព្រះរាជអាជ្ញា** មេត្តាជ្រាបថា: កាលពីថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៧ ជិតដល់ថ្ងៃសែនឆេងម៉េងខ្ញុំបាទបានទូរស័ព្ទទៅម្តាយមីងឈ្មោះ ស្នើសុំការអនុញ្ញាត្តពីម្តាយមីងដើម្បីធ្វើការចាក់ដីជុំវិញផ្នូរម្តាយរបស់ខ្ញុំបាទដែលស្ថិតនៅក្នុងភូមិស្វាយជ្រំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល (**ផ្នូរម្តាយរបស់ខ្ញុំបាទបញ្ចុះលើដីម្តាយមីងខ្ញុំបាទ**)ពេលនោះម្តាយមីងខ្ញុំបាទ ក៏បានអនុញ្ញាត្តឲ្យខ្ញុំបាទធ្វើការចាក់ដីជុំវិញផ្នូរម្តាយរបស់ខ្ញុំបាទដែលមានទីតាំងក្នុងភូមិ,ឃុំខាងលើ លុះថ្ងៃបន្ទាប់ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៧ ម៉ោងបីរសៀលខ្ញុំបាទក៏បានទូរស័ព្ទឲ្យឡានគេចូលចាក់ដីបានចំនួន០៣(បី)ឡាន ពេលដែលកំពុងតែចាក់ដីនោះក៏ត្រូវបានឈ្មោះ បានមកធ្វើការហាមឃាត់មិនឲ្យចាក់ដីបន្តទៀតឡើយដោយគាត់បានអះអាងថាដីខាងលើជាដីរបស់គាត់ ទាំងដែលដីខាងលើជាដីកម្មសិទ្ធិស្របច្បាប់

ចំណារ ស្លាក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១អក
ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

អធិការដ្ឋាននគរបាលស្រុកមុខកំពូល
ចូល លេខ..348...... ថ្ងៃទី......ខែ......ឆ្នាំ២០២០ ម៉ោង......នាទី

# ដីកាកោះ

**យើង** **តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**

ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល
ចូល **អញ្ជើញឈ្មោះ** : ថ្ងៃទី...... ខែ...... ឆ្នាំ...... ម៉ោង **អោយចូលទៅ** : លេខ.................. ន.ប

ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ជា **ជនសង្ស័យ**។

អយ្យការអមសាលាដំបូងខេត្តកណ្ដាល
នៅថ្ងៃទី *២២ ខែ តុលា ឆ្នាំ ២០២០* វេលាម៉ោង **០២.០០នាទី រសៀល**។

**ដើម្បីសាកសួរ** : ពាក់ព័ន្ធនឹងករណី៖" **ហិង្សាដោយចេតនា** " តាមពាក្យបណ្ដឹងរបស់ឈ្មោះ
និងឈ្មោះ ។

**បញ្ជាក់** : សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ អោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តកណ្ដាល ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០
**តំណាងអយ្យការ**

យើង ,
ឈ្មោះ.................................................................... បានប្រគល់ដីកាកោះនេះអោយ
................ភេទ...... អាយុ65ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ ភូមិ............ ឃុំ/សង្កាត់..................
ស្រុក/ក្រុង............ខេត្ត/រាជធានី............នៅថ្ងៃទី 01 ខែ 10 ឆ្នាំ 2020 ផ្ទាល់រូបមកហើយដោយយើងបានទុកចុងដីកានេះមួយច្បាប់អោយសាមីខ្លួន ហើយប្រាប់ថា អោយសាមីខ្លួនប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់តុលាការ ឬ អយ្យការ។

**អ្នកទទួល**
ហត្ថលេខា ឬ ស្នាមម្រាមដៃ

**អ្នកប្រគល់**
ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ:១៥៣១អក
ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

# កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ម្ភៃ ខែតុលា ថ្ងៃទីម្ភៃពីរ វេលាម៉ោង ដប់បួន និង សូន្យ នាទី រសៀល

**យើង** **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល**

ដោយមានលោក ជាក្រឡាបញ្ជី អមផង បានសួរកត់យកចម្លើយរបស់៖

| | |
|---|---|
| នាមត្រកូលនិងនាមខ្លួន | ៖ ភេទប្រុស អាយុ ៦៧ឆ្នាំ ជា ជនសង្ស័យ។ |
| ជនជាតិ | ៖ ខ្មែរ / សញ្ជាតិ៖ ខ្មែរ មុខរបរ៖ នៅផ្ទះ លេខទូរស័ព្ទ: ។ |
| ប្រពន្ធឈ្មោះ | ៖ មានកូន ៤នាក់ ។ |
| ទីកន្លែងកំណើត | ៖ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ។ |
| ទីលំនៅបច្ចុប្បន្ន | ៖ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល។ |
| ឪពុកបង្កើតឈ្មោះ | ៖ ម្តាយឈ្មោះ ។ |
| កំរិតវប្បធម៌ | ៖ ថ្នាក់ទី៦ចាស់ / ទោសពីមុន៖ មិនមាន។ |

សួរ/ឆ្លើយ៖ ខ្ញុំបាទ ត្រូវជាពូបង្កើតរបស់ឈ្មោះ ភេទស្រី អាយុ ៣២ឆ្នាំ ព្រោះឪពុករបស់នាងគឺជាបងបង្កើតរបស់ខ្ញុំ រីឯឈ្មោះ ត្រូវជាកូនរបស់បងស្រីខ្ញុំបង្កើតឈ្មោះ ។

សួរ/ឆ្លើយ៖ នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧ វេលាម៉ោង៤រសៀល ឈ្មោះ បានហៅឡានដឹកដីទម្ងន់៥តោនឱ្យយកដីមកចាក់នៅលើដីរបស់បងស្រីខ្ញុំឈ្មោះ ចំនួន៥ឡាន និងចាក់នៅជុំវិញផ្ទះរបស់បងស្រីខ្ញុំឈ្មោះ និងត្រូវជាម្តាយរបស់ឈ្មោះ ចំនួន០៥ឡានដែរ។ ពេលឃើញចាក់ដីដូចនេះ ខ្ញុំបាទម្នាក់ឯងបានដើរទៅសួរនាំឈ្មោះ ដោយសារផ្ទះខ្ញុំនៅក្បែរនោះដែរ ហើយខ្ញុំក៏សួរថា *ហេតុអ្វីហ្អែងមកចាក់ដីនៅទីនេះ ក្នុងគោលបំណងអ្វី* ? ប៉ុន្តែឈ្មោះ បានឆ្លើយតបមកខ្ញុំដោយពាក្យមិនសមរម្យថា *អាញ់ចាក់ដីស្រេចតែអាញ់ គ្មានទើសក្បាលកណ្តួយម៉ែអាណាទេ។* ខ្ញុំក៏បានប្រាប់ឈ្មោះនោះថា *បើចង់ជេរ ជេរត្រឹមអាញ់ បានហើយកុំជេរដល់ម៉ែអាញ់* វាក៏ឆ្លើយថា *ស្រេចតែអាញ់* ហើយ ខ្ញុំក៏ប្រាប់វាថា *ប្រយ័ត្នអាញ់វាយ* វាក៏បានឌឺខ្ញុំថា *ហែងវាយមកៗ* ពេលនោះខ្ញុំក៏ទាញករអាវឈ្មោះ ប៉ុន្តែមានឈ្មោះ ជាម្ចាស់ឡានដឹកដីបានមកអោបខ្ញុំពីក្រោយ ហើយឈ្មោះ បានយកដុំឥដ្ឋតាន់មួយដុំមកវាយក្បាលខ្ញុំបែកចំនួន ០៤ថ្នេរ ហើយឈ្មោះ ក៏បានរត់ចេញពីកន្លែងកើតហេតុ ចំណែកឈ្មោះ ក៏បានយកដុំថ្មបំរ៉ុងគប់មកលើខ្ញុំទៀត ប៉ុន្តែមិនហ៊ានគប់ក៏រត់ចេញពីផ្ទះគេចមកនៅភ្នំពេញបាត់។

សួរ/ឆ្លើយ៖ ដីដែលសាងសង់ផ្ទះនោះគឺជាកម្មសិទ្ធរបស់បងស្រីរបស់ខ្ញុំឈ្មោះ                សព្វថ្ងៃគាត់រស់នៅជាមួយខ្ញុំ ដោយសារគាត់មិនមានប្តី និងកូនទេ។ ចំពោះមូលហេតុដែលសាងសង់ផ្ទះនៅលើដីរបស់ឈ្មោះ ហ៊ាង ឡេងហួយ ដោយសារតែឈ្មោះ                និងឈ្មោះ                ត្រូវជាបងប្អូនបង្កើតជាមួយគ្នា ហើយណាមួយហ៊ុងស៊ុយចិនសែនបានទាយថាអាចសង់ផ្ទះបានតែនៅលើទីតាំងដីនោះតែប៉ុណ្ណោះ                មិនអាចធ្វើកន្លែងផ្សេងបាន។

សួរ/ឆ្លើយ៖ គោលបំណងដែលខ្ញុំទៅសួរគេរឿងចាក់ដីនោះគឺគ្រាន់តែចង់ដឹងថាគេចាក់ដីដើម្បីធ្វើអ្វី ហើយគ្រាន់ចង់ដឹងថាគេចាក់នោះមានសុំម្ចាស់ដីគេហើយឬនៅតែប៉ុណ្ណោះ។ ខ្ញុំមិនដែលគិតថាដីដែលសាងសង់ផ្ទះរបស់បងស្រីខ្ញុំនោះជាដីរបស់ខ្ញុំម្តងណាទេ ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ដប់ប្រាំ និង សូន្យ នាទី នាថ្ងៃខែឆ្នាំដដែល។

បានអានឱ្យសាមីខ្លួនស្តាប់ឆ្លើយថាត្រឹមត្រូវហើយ ហើយយល់ព្រមផ្តិតម្រាមដៃឬចុះហត្ថលេខាជាមួយយើង។

**អ្នកឆ្លើយ**

**ក្រឡាបញ្ជី**

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្ដាល**

លេខ៖ ០៨៤.. ដក.សប

# ដីកាសម្រេចបញ្ចូលសំណុំរឿង[1]

**យើង** **តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**

-**បានឃើញ៖** សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១ អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ដែលមានឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ៣២ឆ្នាំ ជាដើមបណ្ដឹងរដ្ឋប្បវេណី និងឈ្មោះ ភេទប្រុស អាយុ ៦៥ឆ្នាំ ជាជនសង្ស័យ ពាក់ព័ន្ធនឹងករណី ហិង្សាដោយចេតនា ប្រព្រឹត្តនៅ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ។ *(សំណុំរឿងនៅដំណាក់កាលអយ្យការ)*

-**បានឃើញ៖** សំណុំរឿងព្រហ្មទណ្ឌលេខៈ ១២១០ អ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានឈ្មោះ ភេទប្រុស អាយុ ៦៣ឆ្នាំ ជាដើមបណ្ដឹងរដ្ឋប្បវេណី និងឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ ជាជនត្រូវចោទ ពាក់ព័ន្ធនឹងករណី ហិង្សាដោយចេតនា ប្រព្រឹត្តនៅ ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ។ *(សំណុំរឿងនៅដំណាក់កាលចៅក្រមស៊ើបសួរ)*

## ក្រោយពីបានពិនិត្យសំណុំរឿងខាងលើរួចមក

-**យល់ឃើញថា៖** សំណុំរឿងទាំងពីរខាងលើ គូរភាគីទំនាស់បានប្ដឹងគ្នាទៅវិញទៅមក ទីកន្លែងប្រព្រឹត្ត និងអំពើល្មើសដូចគ្នា។ ម្យ៉ាងទៀតសំណុំរឿងទាំងពីរនេះ មិនទាន់មានសំណុំរឿងណាមួយត្រូវបានតុលាការបើកសវនាការនៅឡើយទេ។

-**យល់ឃើញថា៖** ដើម្បីងាយស្រួលក្នុងកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត និងជៀងវាងចំណាត់ការសំណុំរឿងពីរដែលមានគូរភាគីក្នុងអង្គហេតុដដែលៗ គប្បីបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១ អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ១២១០ អ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ទៅជាសំណុំរឿងតែមួយ។

## ហេតុដូចនេះសម្រេច

-បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៣១ អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ១២១០ អ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីចាត់ការតាមផ្លូវច្បាប់ ។

ថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ខេត្តកណ្ដាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

**តំណាងអយ្យការ**

---

[1] មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្ដីពីការបញ្ចូលនីតិវិធី ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ ៖......4769...............

# ដីកាសម្រេចមិនឃុំខ្លួន

**យើង ម្លុខ ចិសាល** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

-បានឃើញមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៖ ០៤០ ដកសស ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញកំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ។

*ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា:*

ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ឪពុកឈ្មោះ ម្ដាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន ០៤នាក់ ជានីតិជន ។

ត្រូវជាប់ចោទពីបទ ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**<u>យល់ឃើញថា:</u>**

-បទល្មើសជាបទមជ្ឈិម

-ជននេះមិនបង្កការលំបាកដល់ការស៊ើបសួរ

-ជននេះមានអាសយដ្ឋាន និងមានមុខរបរពិតប្រាកដ

-ការសម្រេចមិនឃុំខ្លួននេះ មិនប៉ះពាល់ដល់នីតិវិធីរបស់តុលាការទេ

**<u>ហេតុដូច្នេះសម្រេច</u>**

-មិនឃុំខ្លួនឈ្មោះខាងលើ ដោយអនុញ្ញាតឱ្យមានសេរីភាពធម្មតាវិញ តែត្រូវឱ្យឈ្មោះនេះចូលទៅបង្ហាញខ្លួននៅចំពោះមុខសាលាដំបូងជាដរាប កាលណាមានដីកាកោះហៅ ។

ថ្ងៃអង្គារ ៨រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ

កណ្ដាល ថ្ងៃទី...08...ខែ...ធ្នូ.....ឆ្នាំ២០20...

ព្រះរាជអាជ្ញារង

៣០

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

# ដីកាបង្គាប់ឱ្យចូលខ្លួន

លេខ 24.18.

យើង ក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៤០ ដកសស/១៨ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

ចោទប្រកាន់លើជនត្រូវចោទ៖

១.១ ឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រៃកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៦៩ សង្កាត់ទឹកល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ មានកូន ០២ នាក់ ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

១.២ ឈ្មោះ ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រៃកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នផ្ទះលេ ល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្តីឈ្មោះ (រ) មានកូន ០២ នាក់ ម្តាយឈ្មោះ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

១.៣ ឈ្មោះ ភេទប្រុស អាយុ ៦៧ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ នៅផ្ទះ មានទីកន្លែងកំណើតនឹងទីលំនៅបច្ចុប្បន្នភូមិស្វ ស្រុកមុខកំពូល ខេត្តកណ្តាល ពោះម៉ាយ មានកូនចំនួន ០៤ នាក់ ឪពុកឈ្មោះ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ: **ហិង្សាដោយអចេតនា** ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រៃកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

បង្គាប់មកឈ្មោះ ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ២៦៩ សង្កាត់ទឹកល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ឱ្យចូលខ្លួនទៅកាន់សាលាដំបូងខេត្តកណ្តាលនៅថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០២០ វេលាម៉ោង ០៩ នឹង ៣០ នាទីព្រឹក ដើម្បីសាកសួរ ពីដំណើររឿងពាក់ព័ន្ធសំណុំរឿងខាងលើ។

បើមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ **យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន**។

ថ្ងៃ ចន្ទ ១៤ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

ក្រឡាបញ្ជី អ៊ឹង ឆ្លងកែវ

ផារាជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក
ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៧
លេខ ៖...521.................

# ដីកាបញ្ជូនព័ត៌មាន

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ឈ្មោះ នឹងឈ្មោះ

ជាជនត្រូវចោទ នៅក្នុងការស៊ើបសួរពីបទៈ ហិង្សាដោយអចេតនា ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

ទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ឬផ្តល់យោបល់លើការបិទការស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២១០ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ។

ថ្ងៃព្រហស្បតិ៍ ០៧ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០២១
ចៅក្រមស៊ើបសួរ

**យោបល់របស់តំណាងអយ្យការ**

យើង.... .ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល ។
បានឃើញដីកាបញ្ជូនព័ត៌មានខាងលើ
បានឃើញសំណុំរឿងស៊ើបសួរលើឈ្មោះ......... ...............................
ក្រោយពីបានពិនិត្យសំណុំរឿងស៊ើបសួរចប់ ស្នើសុំ ៖
...............................................................................................

ថ្ងៃ..................ខែ...........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល ថ្ងៃទី..04.. ខែ..02.. ឆ្នាំ២០..21
ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៖ ១២១០ អក
ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧
លេខ ៖..៦២៤............

# ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

-បានឃើញមាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទិននឹងជនត្រូវចោទ ៖

១.១ ឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៦៩ សង្កាត់ទឹកល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ មានកូន ០២ នាក់ ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

១.២ ឈ្មោះ ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៦៩ សង្កាត់ទឹកល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្តីឈ្មោះ មានកូន ០២ នាក់ ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

១.៣ ឈ្មោះ ភេទប្រុស អាយុ ៦៧ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ នៅផ្ទះ មានទីកន្លែងកំណើត នឹងទីលំនៅបច្ចុប្បន្នភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល មានកូនចំនួន ០៤ នាក់ ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ ហិង្សាដោយអចេតនា ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ឬ ផ្តល់យោបល់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ថ្ងៃព្រហស្បត្តិ៍ ០៧ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

ក្រឡាបញ្ជី [illegible]
[illegible]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ១២១០ អ.ក
ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧
លេខ : ២៤១ ដកសព

# ដីកាសន្និដ្ឋានស្ថាពរ

**យើង តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ ០៤០ ដកសស ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ៖ ០២២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ៖ ៥២១ ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា៖**

១-នាម-គោត្តនាម ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ។ ទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ ម្ដាយឈ្មោះ ។ ប្រពន្ធឈ្មោះ
មានកូនចំនួន ០២នាក់ ។ ☑នីតិជន ។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

២-នាម-គោត្តនាម ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ។ ទីកន្លែងកំណើតភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦៩ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ ម្ដាយឈ្មោះ ។ ប្ដីឈ្មោះ
មានកូនចំនួន ០២នាក់ ។ ☑នីតិជន ។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៣-នាម-គោត្តនាម ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ។ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ឪពុកឈ្មោះ
ម្ដាយឈ្មោះ ។ ពោះម៉ាយ មានកូនចំនួន ០៤នាក់ ។ ☑នីតិជន ។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

